**នេះ**₂ (*ព.ក្ល.៖* នេ, នៃ) **ន.** *នុ៎ះ, ហ្នឹង;*

**ឧទា. នេះគិប់លាសមែមោ អ្យាត់ ។** *ហ្នឹងខ្ញុំថា មិនព្រមស្តាប់។ 'ព្នរ';*

*ព.ដ.គ្រ.៖* នែះ *'ព្រៅ'។*

**នេះឆ្រាច់ ន.** *អនាម័យ;*

*មើល៖* នេះ, ឆ្រាច់។

**នៃ**₁ **ន.** *កណ្តុរ, 'ព្យ៉ាត់';*

*ព.ដ.គ្រ.៖* កានៃ *'រ៉អូង'។*

**នៃ**₂ (*ព.ក្ល.៖* នេ, នេះ, នែ, នែះ)

**សព្វ.** *នេះ, នោះ, ហ្នឹង។*

**នែង**₁ **កិ.វិ.** *រាល់ពេល;*

*មើល៖* នឹងនែង។

**នែង**₂ **ន.** *ចង្កូម, ខ្នាយ;* **ឧទា. នែង នាច នែងឆិ ។** *ខ្នាយជ្រូកព្រៃ ចង្កូមឆ្កែ។ មើល៖* រាមាង់។

**នែងអុញ ន.** *ដែកកេះ។*

**នែត ន.** *ក្រាស, ស្អិត។*

**នែតរាលា** *ស្អិតឫស្សី។*

**នែស**₁ **ឧ.** *ហ៍!។*

**នែស**₂ **ន.** *តំបន់។*

**នែសនិង** *តំបន់ណាង។*

**នែសម្យាត់** *តំបន់ព្យ៉ាត់។*

**នែស**₃ **ន.** *ដី។*

**នែសមោយ** *ធូលីដី។*

**នែសរាដុង** *ដីទំនាប, ទីទំនាប។*

**នែសរាលិម់** *ដីបាក់។*

**នែសលិង់** *ដីរាបស្មើ។*

**នែះ** (*ព.ក្វ.៖* នែ, នេ, នៃ) ***សព្វ.*** *នុំះ, ហ្នឹង, 'ព្រៅស';*

*ព.ជ.គ្រ.៖* នេះ *'ព្នារ'។*

**នៃ** (*ព.ក្វ.៖* នេ, នេះ, នែ, នែះ)

***សព្វ.*** *នេះ, នោះ, ហ្នឹង។*

**នោ** *ន. បងប្រុស។*

**នោង** *ន. ឃ្មោក។*

**តើមនោង** *ដើមឃ្មោក។*

**នោត** *ន. ត្នោត។*

**តើមនោត** *ដើមត្នោត។*

**នោនារ** *ន. រឿងរ៉ាវ។*

**នោប** *ន. ញញួរ។*

**នោលិរ** *ន. រៀមច្បង, កូនប្រុសច្បង។*

**នោស** (*ព.ក្វ.៖*នុស) ***ន.*** *ស្នប់ដំដែក;*

***ឧទា.*** **គិប់មាពោសនោសមិនអឹ មែមាច្បារ់ ។** *ខ្ញុំជាអ្នកសប់ស្នប់ដំដែក ហើយអ្នកជាអ្នកដំ។*

**និង**[1] *ន. ទ្រុងមាន់។*

**និង**[2] *ន. ណាង (ជនជាតិភាគតិចមួយក្រុមអម្បូរព្នង)។*

**និង់** *ន. ធ្នង់, 'ព្យ៉ាត់';*

*ព.ជ.គ្រ.៖* នឹង *'ព្នារ'។*

**តើមនិង់** *ដើមធ្នង់។*

**និប់** *គុ.* ១) *ជាប់;* ***ឧទា.*** **មែកិត់រាឆែ អិន់និប់ ។** *គាត់ចងឱ្យជាប់។ 'ព្នារ';*

*ព.ជ.គ្រ.៖* ជឹ *'ព្រៅស';*

២) *ជាប់រឹងម៉ឹង,* ៣) *ជាប់ស្អិត,*

៤) *ជន់,* ***ឧទា.*** **ឆាសអ្យានិប់ ងាន់ ។** *កាផានេះជន់ណាស់។*

**និម** *ន. ប្រមោយដំរី។*

**និម់** *ធ. ក្រោម។*

**និរ** *ន. ឈើដែលដួលនៅតាមចម្ការ។*

**និរ់** (*ព.ក្វ.៖* អានិរ់) ***គុ.*** *ដូ;*

***ឧទា.*** **ឆិង់និរ់ ។** *ត្រង់ដូ។*

# ប

**បាង់** **ន.** ទំពាំង។
**បាង់ឆ្នោត** ទំពាំងជ្រក់។
**បាត** **គុ.** សម្បើម; **ឧទា.** **ក្ងិង់ទុតអា បាត ។** ធំសម្បើម។
**បាន់** (ព.កួ.៖ មាន់) **ន.** កូនប្រសាស្រី, បងថ្លៃស្រី, ប្អូនថ្លៃស្រី;
ព.ស្រ.៖ មី;
ក.៖ ពិ;
ក.៖ ក្លែ;
មើល៖ បែ។
**បាប** (ខ្ចីពី៖ ខ.) **ន.** បាប;
ព.ជ.៖ តិមពីស។
**បាប់ធិរ់** **កិ.** ណែនាំ, បង្ហាត់បង្រៀន; **ឧទា.** **មូរាញបាប់ធិរ់មាអូរឆាយ មហែ ។** ចាស់ទុំណែនាំប្ដីប្រពន្ធថ្មីថ្មោង។
**បាបើ** **សព្ទ.** រាល់ដង, ញឹកញាប់, ញយដង, ព្នុរ;
ព.ជ.គ្រ.៖ ឆាន់ ព្យ៉ាត់។
**បារ់** **កិ.** ១) វ័ណ្ឌ; **ឧទា.** **រាតៅបារ់ តើមឆី ។** វល្លិវ័ណ្ឌដើមឈើ។
២) រុំក្របួច។

**បារ់នា** **ឈ.** ក្រែងលោ;
ព.ជ.៖ ងខេប។
**បាលោ** (ខ្ចីពី៖ បារ.) **ន.** កាបូបស្ពាយក្រោយខ្នង។
**បាស** **កិ.** ឃ្លាត; មើល៖ តឹមបាស។
**ងខាសបាសងាយ** បំបែកឱ្យឃ្លាតឆ្ងាយពីគ្នា។
**បាះ**₁ **ឧ.** ទៀត, ផង; **ឧទា.** **ខាន់មៃ ជាះយើ ជាះនើនហាន់ពិល់អារី បាះ ។** អ្នកបបួលមីង បបួលនើនទៅលេងផង។
**បាះ**₂ **គុ.** ខ្វះ។
**បាះៗ** ខ្វះៗ។
**បាបាះ** ខ្វះៗ។
**អាបាះ** ខ្វះៗ។
**បឺ**₁ **កិ.** ១) ខ្ពើម; ព្នុរ;
ព.ជ.គ្រ.៖ កាបឺ រ៉ាអូង;
២) អាក្រក់។
**បឺបើច** ខ្ពើមរអើម។
**បឺ**₂ **កិ.វិ.** អត់, ទេ, ណាង;
ព.ជ.គ្រ.៖ មោ ព្នុរ។

**បឹត** *គិ. បើក*; ***ឧទា.*** **គិប់បឹតមោតោ។** *ខ្ញុំបើកម៉ូតូ។*

**បឹតលឹត** **ន.** *មួយស្របក់, មួយសន្ទុះ, រំពេចនោះ។*

**បឺ** *គិ. ធ្វើ។*

**បឺម្រាស** *គោរពបូជា។*

**បឺអ្រ្យុស** *បំផ្លាញ។*

**បុកទុកឆ្វីស** *គិ. រអ៊ូរទាំ, និយាយខ្សឹបៗ; មើល៖* ឆ្វីស។

**ងើយបុកទុកឆ្វីស** *រអ៊ូរទាំម្នាក់ឯង (អ្នកជំងឺសរសៃប្រសាទ)។*

**បុន** (*ខ្ចីពី៖ ខ.*) **ន.** *បុណ្យ។*

**បុរ** **ន.** *គុម្ពោត; ព.ជ.៖* រាលោ។

**បើ** (*ខ្ចីពី៖ ខ.*) **ន.** *អាវ៉ូកាត់, បឺរ។*

**បើក** *គិ. លែង; ព.ជ.៖* មអើក។

**បើច** *គិ.វិ. រអើម; មើល៖* បឺ។

**បើស** ***ឧ.*** *ពាក្យប្រើជាមួយ* "នទ្រើ"។

**បេស** *គិ. ជុំក្ងិន, វ៉ាអូង; ព.ជ.គ្រ.៖* បោ *ព្នុរ។*

**បែ** ***សព្វ.*** *អ្នក (សម្រាប់និយាយជាមួយនឹង ឪពុកម្ដាយក្មេក បងថ្លៃ ឬ ប្អូនថ្លៃ);* ***ឧទា.*** **ខាន់បែជាៈ អូរបែអីនែហាន់អ្វាញ់អូបែអារី?** *ម៉េចមិនបបួលប្រពន្ធទៅមើលម្ដាយក្មេក? ព.ជ.៖* មែ, អែ; *មើល៖* ពិ, បាន់, ក្លែ។

**បែក** **ន.** *ត្របែក។*

**បែង** (*ព.ក្ង.៖* ងខែង) **ឈ.** *បែរជា, ទៅជា;* ***ឧទា.*** **បែងពាង់មាមឺចរាមិត គិប់ ។** *វាបែរជាមើលងាយខ្ញុំទៅវិញ។*

**បៃរី** (*ព.ក្ង.៖*អាបៃ) ***គិ.វិ.*** *ឥឡូវនេះ; ព.ជ.៖* បៃអ្យា។

**បៃអ្យា** *គិ.វិ. ឥឡូវ; ព.ជ.៖* បៃរី។

**បោ** **ន.** *ក្ងិន, ជុំ, ព្នុរ; ព.ជ.គ្រ.៖* បេស *វ៉ាអូង។*

**បោកាស** *ជុំក្ងិនឈ្មុយ, ជុំក្ងិនក្រអូប។*

**បោច្រិ** *ជុំក្ងិនឆ្អាប។*

**បោគ្រាត** *ជុំក្ងិនជូរ។*

**បោលាអីរ** *ជុំក្ងិនផ្អូម។*

**បោអោម** *ជុំក្ងិនស្អុយ។*

**បោអៀស** *ជុំក្ងិនអាក្រក់។*

**បៅ** (*ព.ក្ង.៖* បាវ, *ខ្ចីពី៖ ខ.*) **ន.** *បាវ;* ***ឧទា.*** **ឆិះបៅមាតិមា ។** *យកបាវមកច្រកស្រូវ។*

**បិក** (*ខ្ចីពី៖ ខ.*) ***គិ.*** *បោក។*

**បិង់** *គិ. ទុកឱ្យ, បណ្ដោយឱ្យ។*

**បិង់គិរ** *ឱ្យសេរីភាព។*

**បិត់** **ន.** *សិន។*

**បិត់ហិះ** *កុំអាល, ចាំសិន;*

**ឧទា.** **បិត់ហិះនហិត ។** *កុំអាល ពន្ទត់។*

**បិន** **ន.** *ភូមិ។*

**បិនតើមគុ** *ភូមិកំណើត។*

**បិនតេសងីសមមិល់** *ទីក្រុង។*

**បិនលាន** **ន.** ១) *អ្នកភូមិ, ប្រជាជន;* ២) *មនុស្សសាមញ្ញ;* **ឧទា.** **គិប់គុ បិនលានទើម មោហោមជាន ការ ។** *ខ្ញុំរស់ជាមនុស្សសាមញ្ញ លែងធ្វើការ។*

**បិយ**១ **ន.** *កំប៉ុង។*

**បិយ**២ **កិ.** *តាម។*

**បិយអើម** **កិ.វិ.** *ដូចដើម;* **ឧទា.** **ពាង់ ជានអិន់អ្វែសបិយអើម ។** *គាត់ធ្វើ ឱ្យល្អដូចដើម។*

**បិរ** (*ខ្មីពីៈ ខ.*) **កិ.** *បើកបរ, បរ;* **ឧទា.** **គិប់បិររាទែសនទ្រោក ។** *ខ្ញុំបររទេសគោ។*

**បិល់** (*ព.ក្ង.៖* បាល់) **គុ.** *រឹល។*

**បិស** **កិ.** *ត្របាក់។*

**បិសឱប់** *ត្របាក់គ្រឹប។*

**ប្យាៈលាស** **ឈ.** *ប៉ុន្តែ, ព្រែស;* *ព.ជ.គ្រ.៖* យើនមា *ព្នុរ។*

**ប្រាក** **កិ.វិ.** *ពាក្យប្រើជាមួយ "មផិក់";* *ព.ជ.៖* ប្រូក; *មើលៈ* មផិក់។

**ប្រឹង** **កិ.វិ.** *ព្រាង, ព្រាងៗ;* *មើលៈ* អាង។

**ប្រឺ** **កិ.វិ.** *ព្រើត។*

**ប្រុង** **កិ.វិ.** *ស្ទោក;* *មើលៈ* នទ្រ។

**ប្រុច** **កិ.វិ.** *អាការថយក្រោយ។*

**ប្រូក** **កិ.វិ.** *ពាក្យប្រើជាមួយ "មផិក់";* *ព.ជ.៖* ប្រាក; *មើលៈ* មផិក់។

**ប្រើច** **កិ.វិ.** *បន្តិចម្តង។*

**ប្រិង់** **កិ.វិ.** *យ៉ែ;* *មើលៈ* នតែរ, លុង។

**ប្លារ** **គុ.** *ខ្ជិល, ព្នុរ;* *ព.ជ.គ្រ.៖* កើរ *ណាង;* *ព.ជ.៖* រាលែស។

**ប្លឺស** **កិ.វិ.** *ពាក្យប្រើដើម្បីបង្ហាញពី អាការផាកយ៉ាងលឿន;* *មើលៈ* ងគឹល។

**ប្លឹត** **គុ.** *ស្អិត, ស្អិតល្អួត។*

**ប្ដី** *កិ.វិ. ឡើង;* ***ឧទា.*** **ពាង់ទឹករេស ប្ដី ។** *គាត់រស់ឡើងវិញ។* *មើល៖* រេស។

**ប្ដីរ** *កិ.វិ. ត្រដែត;* *មើល៖* ព្រេស។

**ប្ដុសប្ដុន** (*ព.ក្វ.៖* ប្ដុសប្ដុនគុនគាន់) ***កិ.វិ.*** *ពាក្យប្រើដើម្បីបង្ហាញពីអាការធ្វើមិនដឹងមិនព្ញ។*

**ប្លួតប្លិត** *កិ.វិ. ត្រមង់ត្រមោច, ម្នាក់ឯង;* ***ឧទា.*** **ពាង់គុកិបប្លួតប្លិត ។** *គាត់អង្គុយត្រមង់ត្រមោចម្នាក់ឯង។*

**ប្លែតប្លិត** *កិ.វិ. ក្រឡិចក្រឡុច។* *មើល៖* លើស។

**ប្លែបៗ** *កិ.វិ. ភ្លែមៗ;* *មើល៖* ញធិត់។

**ប្លិត់** *កិ.វិ. ភ្លែត;* ***ឧទា.*** **ទូប្លិត់តានៃ ។** *មួយភ្លែតក្រោយមក។*

**ប្ដាង់** ***ឧ.*** *សំឡេងធ្វើនឹងមាត់ដូចសំឡេងបាញ់ស្នា។*

**ប្ដីតអាង** **ន.** *ភ្លឺស្រាងៗ;* ***ឧទា.*** **អើមអោយប្ដីតៗអាង ។** *ព្រឹកព្រលឹមស្រាងៗ។*

**ប្ដីស** *កិ.វិ. ខ្វាក;* *មើល៖* ពឹ, កាស។

**ប្ដីរ** *កិ.វិ. រឹង;* *មើល៖* នតុប។

**ប្ដុក** *កិ.វិ. ប្រាវ;* *មើល៖* ក្លាស។

**ប្ដុច** *កិ.វិ. ប្រូច;* *មើល៖* លោស។

**ប្ដុត** *កិ.វិ. ភ្លែត;* *មើល៖* ញធាត់, ម្រោះ, រាទោស។

**ប្ដុល** *កិ.វិ. ភ្លាម, មួយរំពេច;* *មើល៖* ពិត់, ទើយ, ទើល។

**ប្ដុលប្ដាល់** (*ព.ក្វ.៖* ប្ដុលប្ដិល់) **ឧ.** *(ពាក្យស្វាគមន៍ឬជម្រាបសួរភ្ញៀវ);* ***ឧទា.*** **ប្ដុលប្ដាល់មែហាន់ បិនហេន ។** *ខ្យល់អីបក់ឱ្យអ្នកមកដល់ភូមិខ្ញុំ។ (ភាសានិយាយ)*

**ប្ដុស** *កិ.វិ. ភ្លែត;* ***ឧទា.*** **នទ្រោករាទុស ប្ដុស ។** *គោស្ទុះដេញភ្លែត។*

**ប្ដើយ** *កិ.វិ. ដោយមិនបង្ខំ, ខ្សុយ;* *មើល៖* អុច, នអើច។

**ប្ដោយ** *គុ. បន្តិចបន្តួច។*

**ប្ដិយ** ***ឧ.*** *សោះ;* ***ឧទា.*** **គុតាអ្យា ប្ដិយ ។** *នៅហ្នឹងសោះ។* *ព.ដ.៖* ច្រាវ។

**ប្ដិះ** *កិ.វិ. ពាក្យប្រើដើម្បីបង្ហាញពីអាការដឹងខ្លួនពីសន្ទប់/ស្លាប់ ហើយចាប់ផ្ដើមនិយាយស្ដី;* *មើល៖* ងើយ។

**ប្លែ** *កិ.វិ. ភឹល;* *ព.ដ.៖* ខ្វេរ; *មើល៖* មពារ់។

# ផ

**ផាង** ន. *គ្រោះរាំងស្ងួត។*

**ផាឆា** (*ខ្ចីពីៈ ខ.*) **ន.** *ផ្សារ។*

**ផាត**₁ *កិ. រំលើក;* **ឧទា. ពាង់ងើយ ផាតអីមាល់ពាង់ទោលឆោង ។** *គាត់និយាយរំលើកគ្នារបស់គាត់នៅពេលហូប។*

**ផាត**₂ *កិ. ដាប់។*

**ផាន** ន. *ព្រលឹង, វិញ្ញាណ។*

**ផាន់** ន. *បំណុល;* **ឧទា. ពាង់អោប ផាន់ ។** *គាត់ទារបំណុល។*

*ព្យ៉ាត់;*

*ព.ដ.គ្រ.៖* រានិន *ឮរ។*

**ផានុមពេញ** (*ខ្ចីពីៈ ខ.*) **ន.** *ភ្នំពេញ;* **ឧទា. ហាន់អាមពេញ ។** *ទៅភ្នំពេញ។* *ព.ដ.៖* មពេញ។

**ផាម** *គុ. ប្រាំបី (៨)។*

**ផាយ** *កិ. ទាញចេញ។*

**ផាល** (*ខ្ចីពីៈ ខ.*) **ន.** *ផាល;* **ឧទា. ផាល ងគិល់ ។** *ផាលនង្គ័ល។*

**ផាលាស** **ឧ.** *ល្ហើយ, ក៏ហីចុះ;* **ឧទា. លាសមោអុចរាវាត់ផាលាស ។** *បើមិនចង់ទិញក៏ហីចុះ។*

**ផារ** ន. *កាំភ្លើង។*

**ផារតោ** *កាំភ្លោះ។*

**ផារវាឆែនតោ** *ខ្សែជង្ហក់។*

**ផឹង** ន. *គេ។*

**ផឹត** *គុ. ភ័យ។*

**ផឹច**₁ **ឧ.** *សំឡេងស្តោះ។*

**ផឹច**₂ *កិ. សំឡេងស្តោះ។*

**ផឹរ** *កិ.វិ. ពាក្យដែលបង្ហាញពីអាការៈរបូតចេញ;* **ឧទា. មេសរីសផឹរ មើសតើមឆី ។** *ពស់របូតពីដើមឈើ។* *មើលៈ* រីស។

**ផុង** ន. *ឃ្ងង់។*

**ផុត** ន. *ព្យុះ។*

**ផុតច្វាញ់** *ព្យុះគួច, ព្យុះកំបុតត្បូង។*

**ផ្ទង** ន. *ក្រុម, ហ្វូង, ពួក។*

**ឆុរផ្ទង** *ហ្វូងជ្រូក។*

**មពោលផ្ទងច្រិស** *ពួកគ្រិស្តបរិស័ទ។*

**ផ្ទងច្បៅមែង** *អ្នកជិតខាង;*

*ព.ដ.៖* ច្បៅមែង, មូច្បៅមា;

*មើលៈ* អិសនោច្បៅមា។

**ផ្ទងញជេស** *ពួកហោរា។*

**ផើរ** *កិ. ផ្អើល;* **ឧទា. រាវែសផើរតាង់ញហាង់ឆ្មុម!** *ដំរីផ្អើលដោយសារឮសំឡេងសត្វ!*

**ផៃ** **ន.** *អង្ករ;*

*ជ.ក.៖* ផៃ, ព្យាង់, មា។

**ផៃមអេត** *អង្ករដំណើប។*

**ផៃមិក** *អង្ករសម្រិត, អង្ករស។*

**ផោម** *កិ.* ១) *ផោម,*

– **ន.** ២) *ផោម។*

**ផោយ** (*ខ្ទីពី៖ ខ.*) **ន.** *ក្ដួយ។*

**ផោល** (*ព.ក្ង.៖* មផោល) *កិ.* ១) *ផ្ដុំ;* **ឧទា. ផោលពុកទុង ។** *ផ្ដុំប៉េងប៉ោង។*

២) *ជប;*

**ឧទា. ពាង់ឆិះគុនផោលជេងកា ។** *គាត់យកប្រទាលជបទៅជាត្រី។*

**ផិង** *កិ. ប្ដឹង, ព្នរ;*

*ព.ជ.គ្រ.៖* កាចុត *វ៉ាអូង។*

**ផិង់** *កិ. សម្លឹង;* **ឧទា. កិនឆែផិង់មាត់រាវលាវ ។** *ក្មេងសម្លឹងមុខខ្លែរ*

**ផិប** *កិ. ជ្រលក់; ព.ជ.៖* ញិម។

**ផ្សើ** *កិ. សែន។* **ឧទា. តិប់ផ្សើមាម្រាស ។** *ខ្ញុំសែនអារក្ស។*

**ផ្សៀ** (*ព.ក្ង.៖* ប្អៀ) **កិ.វិ.** *រលីង។*

# ព

**ពា** (*ព.កួ.៖* មពា) **ន.** *កន្ទាយ។*

**ពាក**₁ (*ព.កួ.៖* បុនពាក) **ន.** *បុណ្យចម្ងង, បុណ្យប៉ាកភាសាជនជាតិ ហេប្រឺ។*

**ពាក**₂ *កិ.វិ. ផាំង; មើល៖* ផ្រែស។

**ពាក់** *កិ. ដក;* **ឧទា. ឃើពាក់អេបតាមីរ ។** *មីងដកស្មៅក្នុងចម្ការ។*

**ពាក់ចិម់** (*ខ្ចីពី៖ ខ.*) **ន.** *បបម។*

**ពាង**₁ **ន.** *ត្បែង។*

**តើមពាង** *ដើមត្បែង។*

**ពាង**₂ *កិ. កាល់, ភាំង, ការពារ។*

**ពាង់**₁ *សព្វ. គាត់។*

**ពាង់**₂ **ន.** *សម្បុក;* **ឧទា. ឆុតទូពាង់ ។** *ឃុំមួយសម្បុក។*
*ព.ស្រ.៖* ព្យាត។

**ពាច** *កិ. ប្រោះ; មើល៖* រាពុស។

**ពាច់** *កិ. ក្រង។*

**ពាញ់** *កិ. បាញ់។*

**ពាដុង** **ន.** *ប៊ីដុង។*

**ពាត់** *កិ.* ១) *ពូត;* **ឧទា. ពាត់អារម៉ែះ ។** *ពូតអាវទទឹក។* ២) *ពូត;* **ឧទា. ពាត់ព្យាង់មអេត ។** *ពូតបាយដំណើប។*

**ពាន់** *កិ. ក្រាប។*

**ពាន់រាដ្ឋិប់** *ក្រាបស្រពាប;* **ឧទា. អែរពាន់រាដ្ឋិប់ ។** *ឆ្មាក្រាបស្រពាប។*

**ពាប** **ឧ.** *សំឡេងទាស្រែក។*

**ពាប់** *កិ.វិ. ពឹប; មើល៖* ចុច។

**ពាម** **ន.** *ទ្រូ។*

**ពាម់**₁ *កិ. លង់ទ្រនេស។*

**ពាម់**₂ *កិ.វិ. មានតែ;* **ឧទា. ពាម់អេងមហាមមែទើមទើយតឹមច្វាយ ។** *មានតែឈាមព្រះអង្គទេដែលអាចសង្គ្រោះបាន។*

**ពាយ** *កិ. លាយម្សៅសម្រាប់ធ្វើសម្ល;* **ឧទា. ពាយត្រាវ ។** *ធ្វើម្ហូប "ត្រាវពាយ"។*

**ពារាឆីត** (*ខ្ចីពី៖ អ.*) **ន.** *ប៉ារ៉ាស៊ីត។*

**ពាល** *គុ.* ១) *ស្ងួត,* ២) *ហើរពណ៌;* **ឧទា. កែវទាកអ្យាលែះពាល ។** *កែវទឹកនេះហើរពណ៌។*

**ពាលរាតើក** *ស្ងួតស្វាំង។*

**ពាលីស** (*ខ្ចីពីៈ ខ.*) ន. *ប៉ូលីស។*

**ពាស** *កិ. ស្តាប។*

**ពាសកាន** *កិ. ធ្វើការ, 'ព្រែស';* *ព.ជ.គ្រ.៖* ជានការ *'ព្នុរ'។*

**ពាសពុង** *កិ. វាយទឹកលេង។*

**ពាៈ១** *កិ. បែក។*

**តឹមពាៈ** *បែករំលែក;*

*ឧទា.* **ជេសរីខាន់ពាង់គុចឆុរអីរី តឹមពាៈមូទូជាសហែទូជាស ។** *បន្ទាប់មកពួកគេដុតជ្រូកនោះ ហើយបែកគ្នាម្នាក់មួយចំហៀង។*

**ពាៈ២** *កិ. បាក់។*

**ពិច** *គុ. ដែប; ឧទា.* **ពេសពិត ។** *កាំបិតដែប។*

**ពិត** *ន. ក្បែរ។*

**ពីត** *កិ. ដណ្តើម; មើលៈ* អឹន។

**ពីរ** *ឧ. សំឡេងសត្វក្តាន់ ឬ ប្រើស ស្រែក។*

**ពីស១** *កិ. បោកគក់; មើលៈ* តោល។

**ពីសខិពីសអារ** *បោកគក់ខោអាវ។*

**ពីស២** *កិ. នោម, បត់ជើងតូច, 'ព្រែស';* *ព.ជ.គ្រ.៖* ច្រាច *'ព្នុរ'។*

**ពីស៣** *ន. ស្មៅ, តិណជាតិ, 'ព្រែស';* *ព.ជ.គ្រ.៖* រេប *'ព្នុរ'។*

**ពឹក** *កិ.វិ. ផស; មើលៈ* ទែស។

**ពឹង** *កិ. រវាំង, ផ្សៀង។*

**ពឹងតោរ** *រវាំងត្រចៀក, ផ្សៀងត្រចៀក។*

**ពឹត១** *កិ. អាំង, ឆ្អើរ; ព.ជ.៖* ពិរ់។

**ពឹត២** *ធ. ក្បែរ; ឧទា.* **គុតាពឹតមែង ទាក ។** *នៅក្បែរមាត់អូរ។*

**ពឹរ** *កិ. អាំង។*

**ពឹល** (*ខ្ចីពីៈ ខ.*) ន. *ពិល។*

**ពឺ១** *កិ. លើក, 'ព្នុរ';* *ព.ជ.គ្រ.៖* ចោង *'ព្រែស';* *មើលៈ* រើប។

**ពឺហារ** *លើកឡើង។*

**ពឺ២** *កិ. បី; ឧទា.* **ពាង់ពឺអិសចេ ។** *នាងបីកូនងើត។*

**ពឹង១** *កិ.វិ. ភីង។* *មើលៈ* ចោត។

**ពឹង២** ន. *រូង; ព.ជ.៖* ពឹៈ។

**ពឹច** *កិ.វិ. ពាក្យប្រើសម្រាប់បន្ថែមន័យលើកិរិយាស័ព្ទ; មើលៈ* ផ្រែស។

**ពឹម** ន. *គែ។*

**ពឹៈ** ន. *រូង; ព.ជ.៖* ពឹង។

**ពុក** *គុ. ប៉ោង, ហើម។*

**ពុងវែៈ** ន. *កណ្តៀតក្អម។*

**ពុងទាក** ន. *ពោះទឹក។*

**ពុត** ន. *សត្វស្វាបមួយប្រភេទ។*

**ពុន** ន.១) *ពក*,២) *ដើមឈើមួយប្រភេទ។*

**ពុនរាទូត** *ពកស្មុល*; ឧទា. **ពុនមោករាទូត ។** *ពកក្បាលស្មុល។*

**ពុម** គុ. *ស៊ុបទ្រុប។*

**ពុមរាលោធី** *គុម្ពោតព្រៃស៊ុបទ្រុប។*

**ពុរ១** ន. *ផ្សិត*; ព.ដ.៖ ក្លិះ។

**ពុរ២** កិ. *ដុត*; ឧទា. **ពាង់ពុរខិអារឆាត ។** *គាត់ដុតខោអាវចាស់ៗ។*

**ពុរទុត** ន. *អវយវៈភេទស្ត្រី, ទ្វារមាស, យោនី*; ព.ដ.៖ លែន, ឆ្ងូអាច់។

**ពុល** កិ. *លាក់។*

**ពុស** (ខ្ចីពី៖ ខ.) ន. *ប៉ុស្តិ៍។*

**ពុសរាពាស** កិ.វិ. *ព្រួសប្រាស*; មើល៖ លោស។

**ពូ** កិ. *ប៉ោ។*

**ពូតិស** *ប៉ោដោះ។*

**ពូរឹប** *ប៉ោរឹប។*

**ពូក** (ខ្ចីពី៖ ខ.) ន. *ពូក។*

**ពូង** កិ. *ត្រាំកក់។*

**ពូច** (ខ្ចីពី៖ ខ.) ន. *ពូជ។*

**ពូត** កិ. *រុំ*; ឧទា. **ពូតឆោត ។** *រុំរបួស។*

**ពើ** គុ. *សោះ*; ឧទា. **ជិយអាប់នតុកឆៃតាអ្យាពើ ។** *រកគ្រប់កន្លែងបែរជាឃើញនៅនេះសោះ។*

**ពើក** កិ. *បើក។*

**ពើកប្លឹស** *បើកខ្វាក។*

**ពើយ្យ** កិ. *យក។*

**ពើយ្យរឹប** *យករឹប។*

**ពើស១** ន. *សប្តាហ៍, អាទិត្យ។*

**ទូពើស** *មួយសប្តាហ៍, មួយអាទិត្យ។*

**ពើស២** គុ. *ប្រាំពីរ (៧)។*

**ពើសមា** កិ.វិ. *អាល័យតែ*; ព.ដ.៖ ងោយ, ហឹល។

**ពើសមាទ្រោះងាន់** *អាល័យតែដើរ។*

**ពើសអ្ញាញ់** *អាល័យតែមើល*; ព.ក្វ.៖ ពើសមាអ្ញាញ់។

**ពេង** គុ. *ស្អិត។*

**ពេត** កិ. *ខំថែរក្សាបីបាច់, បំប៉ន*; ឧទា. **អ្យារអាបាៈខឹតលៃៈ ខាន់ពាង់ពេតកិនអ្យារលើយអិន់ខឹត ។** *មាន់ផ្សេងងាប់អស់ ពួកគាត់ខំថែរក្សាកូនមាន់មួយកុំឱ្យងាប់។* ព.ដ.៖ តេម។

**ពេប** ន. *ទា*; ព.ដ.៖ កឹក។

**ពេស** *ន. កាំបិត។*

**ពេសកុត** *កាំបិតធំក្រវាត់ចង្កេះ។*

**ពេសងតិរំលាច់** *កូនកាំបិត។*

**ពេសជេះ** *កាំបិតបន្ទោះ។*

**ពេសថាវ** *ពូថៅ។*

**ពេសព្រា** *កាំបិតប៉ុងតោ។*

**ពែ** *គុ. បី។*

**ពែជឹត** *សាមសិប (៣០)។*

**ពែត**₁ (*ខ្ចីពី៖ ខ.*) **ន.** *ពេទ្យ, វេជ្ជបណ្ឌិត។*

**ពែត**₂ **កិ.** *ប្រុបាច់។*

**ពែនឆាត្រឹប ន.** *ប៉ែនសាទ្រិប ឈ្មោះថ្នាំសម្រាប់សត្វ។*

**ពែរ** **ឧ.** *ផាំង, ផាំង;*

*មើល៖* តោប។

**ពែស** **កិ.** *បុកស្រូវ។*

**ពែះ** **កិ.** *បេះ។*

**ពោត** **កិ.** *ដំដែកតូចៗជាច្រើនបញ្ចូលគ្នា ឱ្យទៅជាដែកតែមួយ។*

**ពោទិះ** **ន.** *ប៉េងប៉ោះស្រោម។*

**ពោន** **កិ.** *លាក់ (របស់);*

*ព.ដ.៖* មិ។

**ពោស** (*ព.ក្ង.៖* ពុស) **កិ.** *សប់;*

**ឧទា.** **ពោសកិង់ ។** *សប់កង់។*

**ពោអា** **ឈ.** *ដូច្នេះ។*

**ពិ** **ន.** *ពាក្យសម្រាប់ហៅសាច់ថ្លៃអាយុច្រើនជាងប្ដី ឬ ប្រពន្ធ;*

*ក.៖* ក្លែ;

*ក.៖* បាន់;

*ក.៖* មី;

*មើល៖* វ៉ែរ, បែ។

**មេះពិ** *ម្ដាយក្មេក។*

**មមីពិ** *ឪពុកក្មេក។*

**ពិក** **កិ.វិ.** *ម៉ក; មើល៖* ផ្រែស, តោប, មមាង។

**ពិក់** **កិ.** ១) *កាច់,* ២) *កាប់, ជីក។*

**ពិង់** **កិ.** *ដំ។*

**ពិត** **កិ.** *លាប។*

**ពិតលាយ** **កិ.** *ច្របល់។*

**ពិន់ថើ** **កិ.វិ.** *ព្រងើយ;* **ឧទា.** **ពាង់គុអ្វាញ់វីដេអោពិន់ថើ ។** *គាត់អង្គុយមើលវីដេអូធ្វើព្រងើយ។*

**ពិម់** **កិ.** *វាយពន្ធត់;* **ឧទា.** **បិនលានឆិះងគីងឆីពិម់អុញឆាច្រី ។** *អ្នកភូមិយកមែកឈើវាយពន្លត់ភ្លើងឆេះព្រៃ។*

**ពិយ្យ**₁ (*ព.ក្ង.៖* ព្លៃពិយ្យ) **ន.** *កំភួនជើង។*

**ពិយ្យ₂** *កិ. កោរ។*

**ពិរ** *ន. បបរ។*

**ពិរ់** *កិ. ឆ្អើរ; ព.ដ.៖* ពឹត។

**ពិល់** *កិ. លេង។*

**ពិល់រាលឹន** *លេងល្បែង។*

**ពិល់លិញរិញ** *លេងរលេញ;*

*ឧទា.* **កាពិល់លិញរិញ ។** *ត្រីលេង (ទឹក) រលេញ។*

**ពិស** *កិ.* ១) *បង់; ឧទា.* **កោញនើនពិស មិសតាត្រាវ ។** *ពូនើនបង់អំបិលក្នុងសម្ល។* ២) *ចាក់;*

*ឧទា.* **ក្វាកនែសពិសតានតុកនតូហុក ។** *កើបដីចាក់កន្ទែងមានជង្ហុក។*

**ព្យាង់** *ន. បាយ, ‘ពូរ’;*

*ព.ដ.គ្រ.៖* អិ *‘ព្រៃស’;*

*ដ.ក.៖* ផៃ, ព្យាង់, មា។

**ព្យាង់ក្រា** (*ព.ក្ង.៖* ក្រាព្យាង់) *ន.* *បាយក្តាំង។*

**ព្យាង់មអេត** *បាយដំណើប។*

**ព្យាង់រាលាស** *បាយចុងអង្ករ។*

**ព្យាង់លែត** *បាយទ្រាប។*

**ព្យាត** *ន. ផ្សិត; ឧទា.* **ព្យាតឆុត ។** *ផ្សិតឃ្មុំ។ ព.ស្រ.៖* ពាង់។

**ព្យាត់** *កិ. ក្រង (ស្បូវ); ឧទា.* **គិប់ព្យាត់ ជា ។** *ខ្ញុំក្រងស្បូវ។*

**ព្រា** *ន. ស្ពឹក, រីកមុខ; ឧទា.* **គិប់ចុតងគិង់ងគារ់គែសនគិប់លុព្រា ។** *ខ្ញុំដាំបង្គោលរបងត្រូវប៉ះនឹងថ្មស្ពឹកមុខ។*

**ព្រាក់** (*ព.ក្ង.៖*ព្រាក់កាយ្យ, *ខ្ញីពីះ ខ.*) *ន.* ១) *ប្រាក់; ឧទា.* **ខាល់អ្យាជាន មើសព្រាក់ ។** *ផ្តិលនេះធ្វើពីប្រាក់។* ២) *លុយ; ឧទា.* **ព្រាក់ទ្រោន ។** *លុយខ្មែរ ឬ ប្រាក់ខ្មែរ។*

**ព្រាង់₁** *គុ.* ១) *រាំង; ឧទា.* **ម្រើលែះព្រាង់ ។** *មេឃរាំង (ភ្លៀង) ហើយ។*

– *ន.* ២) *ប្រាំង;*

*ឧទា.* **ខៃព្រាង់ ។** *ខែប្រាំង។*

**ព្រាង់ខឹតព្រាង់ខៅ** *រាំងស្ងួតហួតហែង; ឧទា.* **ម្រើពាង់ព្រាង់ខឹតព្រាង់ខៅ ។** *អាកាសធាតុរាំងស្ងួតហួតហែង។*

**ព្រាង់ផាង** *គ្រោះរាំងស្ងួត។*

**ព្រាង់₂** *ន. បារាំង។*

**ព្រាច់** *កិ. កាត់ផ្តាច់; ឧទា.* **គិប់ព្រាច់រាតៅ ។** *ខ្ញុំកាត់ផ្តាច់រល្ងី។*

**ព្រាប់** *កិ. ទុកដាក់។*

**ព្រាប់ក្លុក** *ទុកដាក់។*

**ព្រាម់** *គុ. ប្រាំ (៥)។*

**ព្រាម់ជឹត** *ហាសិប (៥០)។*

**ព្រាល់**១ *កិ.វិ. រហ័ស។*

**ព្រាល់**២ *កិ.វិ. លឿន។*

**ព្រាវ** *គុ. ប្រាំមួយ (៦)។*

**ព្រាស** *កិ. ដួល។*

**ព្រិ** *កិ.វិ. ផស; មើលៈ* ចាស។

**ព្រីង**១ *ន. ចុះប្រេង;* ***ឧទា.*** **រាវ៉េសតិត់ ព្រីង ។** *ដំរីចុះប្រេង។*

*មើលៈ* ពិត់។

**ព្រីង**២ (*ខ្ចីពីៈ ខ.*) **ន.** *ប្រេង។*

**ព្រីត** *ន. ចេក។*

**ព្រីតកុស** *ចេកណាំវ៉ា។*

**ព្រីតកិប** *ចេកស្នាប់មុខ។*

**ព្រីតឆាស** *ចេកមួយប្រភេទ។*

**ព្រីតឆិង** *ចេកមួយប្រភេទ។*

**ព្រីតឆ្រោត** *ចេកមួយប្រភេទមានរសជាតិជូរ។*

**ព្រីតញជាង** *ចេក;*

*ព.ក្ល.ៈ* ព្រីតត្រុម។

**ព្រីតទុម** *ចេកទុំ។*

**ព្រីតមមុត** *ពន្លកចេក ទើបតែដុះឡើង។*

**ព្រីតល្វាត់** *ចេកនួន;*

*ព.ក្ល.ៈ* ព្រីតអាក់។

**ព្រីតអុញ** *ចេកលក្ខណ៍។*

**ព្រីតងកិៈ** **ន.** *ម្ចាស់។*

**ព្រឹក** *កិ.វិ. រ៉ុយ; មើលៈ* ញច្វាត់។

**ព្រឹត** *កិ.វិ. រត់ទៅ (តែមួយ);*

*មើលៈ* ញច្វាត់។

**ព្រឹប** *កិ.វិ. សំឡេងជំពប់ "ព្រឹប";*

*មើលៈ* ចេស។

**ព្រឹល** *កិ.វិ. ច្រើនរដឹក;*

*មើលៈ* ឆៃ។

**ព្រឺល** *កិ.វិ.* ១) *ចុះឡើង (ត្រីលោតចុះឡើងនៅលើគោក),* ២) *ជំទាស់;*

*មើលៈ* នត្លោះ។

**ព្រុង** *កិ.វិ. សំឡេងធ្លាក់របស់អ្វីមួយ, ប្រាវ; មើលៈ* មអារ់, នអុស។

**ព្រុយ្យ** *កិ.វិ. ខ្លាក;*

*មើលៈ* តុប, ជុយ្យ។

**ព្រូ** *កិ.វិ. ព្រាត;*

*មើលៈ* ហ៊ិន, ដែស, ឆ្វយ។

**ព្រូង** **ន.** *ប្រូង (សម្ល)។*

**ព្រើ** (*ខ្ចីពីៈ ខ.*) **កិ.** *ប្រើ។*

**ព្រេង** *កិ.* *អៀន, ខ្មាស,* *'ព្រែស';*
*ព.ជ.គ្រ.៖* ជីត *'ក្នុរ';*
*ព.ជ.គ្រ.៖* ញ៉ែះ *'ណាង'*។

**ព្រេស** *គុ.* *ខ្ពស់;* *ព.ផ្ទ.៖* ទេស។
**ព្រេសងកួរ** *ខ្ពស់ស្រឡះ។*
**ព្រេសប្លឺវ** *ខ្ពស់ត្រដែត។*

**ព្រែ** *សព្វ.* ១) *របស់គាត់, កម្មសិទ្ធិ របស់គាត់,*២) *គាត់;*
*ព.ជ.៖* ពាង់;
*មើល៖* ពាង់ទែ។

**ព្រែក** *កិ.* *រហែកស្នាមកន្លែងចាស់។*

**ព្រែស** *ន.* *ព្រៃស (ជនជាតិភាគតិច មួយក្រុមអម្បូរព្នង)។*

**ព្រោស** *កិ.វិ.* *ភ្ញាក់ព្រើត (ព្រួស);*
*មើល៖* នទ្រិត់, រាមុល, នគ្លោះ, លោស។

**ព្រិក** *ន.* *កំប្រុក។*

**ព្រិច** *ន.* *ពោះវៀន។*

**ព្រិចញោម** *ន.* *ប្លោកនោម។*

**ព្រិចុម** *កិ.* *ប្រជុំ។*

**ព្រិត**១ *ធ.* *ជិត;* *ព.ជ.៖* កេង។

**ព្រិត**២ *កិ.* *ធ្លាប់, ដែល;*
*ព.ស្រ.៖* លិចនអិក។

**មោព្រិត** *មិនដែល, មិនធ្លាប់;*
*ឧទា.* **មោព្រិតតែសអោសតើមធី អីតើមអ្វែស អីព្លៃមោអ្វែស ។** *មិនដែលមានដើមឈើណាល្អ ហើយផ្លៃមិនល្អទេ។*

**ព្រិវាក** *ន.* *ក្អៀក;* *ព.ជ.៖* ព្លៃវាក។

**ព្រិះ** *ន.* *ស្រឡៅមួយប្រភេទ។*

**ញ្លា** *កិ.* *បិទ, ដាក់ (ស្លាកសញ្ញា, ទីងមោង);* *ឧទា.* **ញ្លារូបចិតតា មពីរ ។** *បិទរូបថតលើជញ្ជាំង។*

**ញ្លាង់** *ធ.* *បំ, ត្រូវ;* *ឧទា.* **ញ្លាង់អ្យាងាន់ គិប់ឆៃពាង់នើស ។** *ខ្ញុំឃើញវានៅ ត្រង់នេះពិតមែន។*
**ញ្លាង់មោក** *ចំក្បាល។*
**ញ្លាង់នតុក** *ចំកន្លែង..., កន្លែងណា?*
**ញ្លាង់ត្រិង** *ចំផ្លូវ..., ផ្លូវមួយណា?*

**ញ្លាច់**១ *កិ.* *ល្បិច, ឧបាយកល;*
*ឧទា.* **លិចម្លាវញ្លាច់ជាសរាចីរីអោស ។** *គ្មានឧបាយកលតទល់នឹងក្រពើទេ។*

**ញ្លាច់**២ *កិ.* *ប្តូរ, ប្រែ;* *ឧទា.* **គិប់ញ្លាច់តួយ នថានមលីកទូជាស ។** *ខ្ញុំប្តូរលើស្នា ម្ខាងទៀត។*

**ញ្លាប់** *កិ.វិ.* *ពាក្យប្រើសម្រាប់បង្ហាញពី អាការៈដែលគេពើបប្រទះអ្វីមួយ*

ដោយចែជន្យ;

មើលៈ តិម, តែស។

**ញ្លាស** កិ. ពុះ, ចែកជាពីរស្មើគ្នា;

**ឧទា. គឺប់ញ្លាសអ្យារ់ទូដាស ។**

ខ្ញុំពុះមាន់ជាពីរ។

**ញ្លាសនតើស** ន. កន្ទះព្យាម។

**ញ្លឹ** កិ. ត្រឡប់មក; **ឧទា. ញ្លឹនាប់ញ្លឹ**

**កើយ ។** ត្រឡប់ទៅត្រឡប់មក។

ព.ប្រ.ជ.៖ **ញ្លឹឆឹត**។

**ញ្លឹខ្ញឹង** ត្រឡប់ក្រោយ (ខ្ញឹង)។

**ញ្លឹប្រោក** ត្រឡប់ក្រោយ (ប្រោក)។

**ញ្លឹប្រុល** ត្រឡប់ក្រោយ (ប្រុល)។

**ញ្លឹក** កិ.វិ. ប៉ាច់, ញ៉ាច់;

មើលៈ តិម។

**ញ្លឹប**១ ឧ. ទឹល; **ឧទា. អុញឆាជាញ្លឹប ។**

ភ្លើងឆេះស្បូវទឹល។

**ញ្លឹប**២ កិ.វិ. ប្ញប់; មើលៈ លែប។

**ញ្លឹន** គុ. ត្រដោល, ទំពែក;

ព.ជ.៖ **ក្លឹន, ង្វូក, ញ្លឹន, លុស,**

**លឹន**។

**ញ្លុក** ឧ. សំឡេងបាញ់ ឬសំឡេង

វាយនឹងរំពាត់, ផស។ ប៉ាប់ៗ។

**ឧទា. រាតិសមមិញ្លុក ។** ផ្ទុះពោត

ផសៗ។

**ញ្លុង**១ ន. ទូក, ណាង;

ព.ជ.គ្រ.៖ **ទូក** ញ្ចុរ។

**ញ្លុង**២ កិ. ឆ្ងាយ។

**ញ្លុយ** កិ.វិ. ប្រុយ; មើលៈ ញច្ចាត់។

**ញ្លួយ** កិ.វិ. ពាក្យបង្ហាញពីអាការ ហើរ

ឬ ហែល; មើលៈ មពារ់, វែ។

**ញ្លើង** កិ. ១) តប, ២) តបស្នង,

៣) សងសឹក, តដៃ;

មើលៈ **ហារ**។

**ញ្លើងអើស** ឆ្លើយតប។

**ញ្លើត** កិ. ប្រែ; **ឧទា. ញ្លើតពាច់នទ្រោក**

**គុច ។** ប្រែសាច់គោអាំង។

**ញ្លើម** ន. ទាក; **ឧទា. ញ្លើមកាប់ឆិ ។**

ទាកទាមឆ្កែ។

**ញ្លេន** ន. បែន។

**ញ្លែរ**១ ន. ព្រិល; ព.ជ.៖ **ម្លែរ**។

**ញ្លែរ**២ គុ. រលោង; ព.ផ្ទ.៖ **រើប**។

**ញ្លែស** កិ. ផ្លាស់ប្តូរ។

**ញ្លែ** ន. ផ្លែ។

**ញ្លែឆាច** ផ្លែផ្សៀវ។

**ញ្លែឆី** ផ្លែឈើ។

**ញ្លែត្រាវ** ផលានុផល។

**ញ្លែមពាត់** ផ្លែម្យ៉ាងនៅក្នុងព្រៃ

សណ្ឋានតូចល្មមហើយមានជាតិ

*ល្វីង គេអាចប្រើសម្រាប់ការពារទាកទាម។*

**ព្លៃមា** *គ្រាប់ស្រូវ។*

**ព្លៃម្វិន់** *គ្រប់។*

**ព្លៃម្វិន់គុរ** *គ្រប់ក្រហម។*

**ព្លៃម្វិន់ព្រុម** *ប៉េងប៉ោះ;* **ឧទា. ព្លៃនោងជេងព្លៃត្រាវទូនតឹល ។** *ឃ្លោកជាបន្លែ (ផ្លែ) មួយប្រភេទ។*

**ព្លៃនួយរ្យ** **ន.** *បេះដូង។*

**ព្លៃវាក** **ន.** *ក្អៀក;* *ព.ជ.៖* ព្រវាក។

**ព្លោក** *កិ.* *ស្មោះ;* **ឧទា. ព្លោកងឱបឆី ។** *ស្មោះសម្បកឈើ។*

**ព្លួយ** *កិ.វិ.* *សំឡេងដើរតែម្នាក់;* *មើល៖* ហាន់។

**ញាច់** **ន.** *សាច់។*

**ញាត់** *កិ.* *កាប់ជាកង់ សម្រាប់តែឈើ។*

**ញាន់** (*ព.ក្ង.៖* ព្វិន់) **គុ.** *បួន។*

**ញាន់ជឹត** *សែសិប (៤០)។*

**ញាល់** *កិ.* *តោង។*

# ម

**មបឹត** (*ព.ក្ន.*៖ មអឹត) **គុ.** *វេទនា, រងទុក្ខ; មើលៈ* ក្រឹត។

**មផារ** **កិ.** *ប្រកែក, រអៀស; មើលៈ* មិ។

**មផារ់** **កិ.** ១) *បង្វិល,* ២) *វិល*។

**មផារ់មាត់ទ្រឹង** *វិលមុខឆេងឆោង*។

**មផារ់មោក** *វង្វេងវង្វាន់, វិលមុខ, ភាន់ភាំង; ព.ដ.*៖ រវាសមោក។

**មផេក** **កិ.** *វែក;* **ឧទា.** **មផេកជាជានត្រិងហាន់ ។** *វែកស្បូវធ្វើផ្លូវដើរ*។

**មផេរ** **កិ.** *តាក់តែង, សម្អិតសម្អាង, ‘ញ៉ាត់’; ព.ដ.គ្រ.*៖ ញឆេរ *‘ញុរ’*។

**មផិក់** **កិ.** *ទាញ*។

**មផិក់ប្រាក** *ទាញដោយកញ្ឆក់ (ពេលមានគ្រោះថ្នាក់)*។

**មផិក់ប្រូក** *ទាញចេញដោយពិបាក;* **ឧទា.** **ពាង់មផិក់ប្រូកពេសតាគ្រោម ។** *គាត់ទាញពស់ចេញពីរន្ធដោយពិបាក*។

**មពា** **ន.** *ចំណីសត្វ*។

**មពាទ្រីឆ្យុមទ្រី** *សត្វព្រៃ*។

**មពាង**$_{១}$ **ន.** *បាតដៃ, បាតជើង*។

**ជិង់លាងមពាងតី** *បាតដៃទទេ*។

**មពាង**$_{២}$ **ន.** *ម្រះ*។

**មពាច** **ន.** *ប្រដាប់សម្រាប់បាចទឹក*។

**មពាញ់** **ន.** *បង្កង់;* **ឧទា.** **ពាង់ឆិះតែ្លជានមពាញ់ច្វាញ ។** *គាត់យកឫស្សីធ្វើបង្កង់ផ្ទះ*។

**មពាត់**$_{១}$ (*ព.ក្ន.*៖ មពិត់) **កិ.** *បម្រះ*។

**មពាត់លេរេលើរើ** *បម្រះរេីរវាយ*។

**មពាត់**$_{២}$ **ន.** *ដើងជុង*។

**មពាត់**$_{៣}$ **ន.** *ពំនូត*។

**ទូមពាត់** *មួយពំនូត*។

**មពាន់** **កិ.** ១) *ភ្ជាស់;* **ឧទា.** **ឆិះតាប់ឤ្យារ់មពាន់មាពេប ។** *យកស៊ុតមាន់មកភ្ជាស់ជាមួយទា*។ ២) *ជួត;* **ឧទា.** **គិប់តាញមិកមពាន់មោក ។** *ខ្ញុំត្បាញកន្សែងដើម្បីជួតក្បាល*។

**មពាន់ក្លឹន** **កិ.** *បំពាក់សក្តិ*។

**មពារ់** **កិ.** *ហើរ*។

**មពារ់ប្លែ** *ហើរភឹល*។

**មពារ់ពួយ** *ហើរ (ពួយ)*។

**មពាល់** **ន.** *ត្បាល់*។

**មពាល់កឹន** *ត្បាល់កិន*។

**មពិច** *កិ. កាច់។*

**មពី** *ន. ពំនូកដី។*

**មពីក** *ន. សំពោច។*

**មពីកពារ់** *ឆ្មាបា។*

**មពីរ** *ន. ជញ្ជាំង។*

**មពីស**$_{១}$ *ន. ចំណារ; ឧទា.* **ឆិះងគីងឆី ជានមពីសទាក់ ។** *យកមែកឈើធ្វើចំណារអន្ទាក់។*

**មពីស**$_{២}$ *ន.* ១) *ពិធីរំដោះគ្រោះ,* – *កិ.* ២) *ជម្រុះកាយ។*

**មពឹក** *កិ. បំតិត។*

**មពឹត** *ន. តម្បុត; ឧទា.* **ស្រែសត្លែជាន មពឹតកា ។** *កាប់ឫស្សីធ្វើតម្បុតត្រី។*

**មពឹះយោក** *ន. ដើងភ្នំ; ឧទា.* **ពាង់ ម្រោះរ៉ះមពឹយោកតែមាតើញតិត់ តាបិនពាដាសយោករី ។** *គាត់ដើរតាមជើងភ្នំដើម្បីឱ្យឆាប់ដល់ភូមិម្ខាងទៀត។*

**មពឹប** *កិ. អណ្ដែតក្ងីងក្នុង។*

**មពុង** *កិ. បង្ហិន។*

**មពុងមពាង់** *បង្ហិនបង្ហោច។*

**មពុញ** *ន. ពពុះ។*

**មពុញរាឆឹក** *ពពុះ។*

**មពុត** *គុ. ពៅ; មើលៈ* កិន។

**មពុយ្ស** *ន. ចម្ការថ្មី; ឧទា.* **មីរមពុយ្ស មហែកាល់ ។** *ចម្ការថ្មីទើបតែកាប់ព្រៃហើយ។*

**មពូ**$_{១}$ *ន. សម្បុក។*

**មពូ**$_{២}$ *កិ. បំបៅ; ឧទា.* **មពូកិនមាទាក តិសមែះ ។** *បំបៅកូននឹងទឹកដោះម្ដាយ។*

**មពូង** *កិ. ជ្រមុជ; ឧទា.* **មពូងរាពូអា ទាកនហិង ។** *ជ្រមុជក្របីក្នុងអូរ។*

**មពូច** *កិ. អុជ;*

*ឧទា.* **មពូចមហិត់ ។** *អុជបារី។*

**មពូន** *ន. ក្បូន។*

**មពើ**$_{១}$ *ជ. ទម្រាំ; ព.ជ.៖* ញអឹ។

**មពើ**$_{២}$ *ឈ. នៅពេលដែល។*

**មពើង**$_{១}$ *ន. ផ្ចិត; ឧទា.* **ពាង់អាញឆុត ព្រាម់មពើង ។** *គាត់ស្លាយឃ្នុំប្រាំផ្ចិត។*

**មពើង**$_{២}$ *កិ. បង្ហើប; ឧទា.* **មោទើយ មពើង ។** *បង្ហើបមិនរួច។*

**មពើល** *កិ. ឃើញ។*

**មពេត** *កិ. សន្សំសំចៃ។*

**មពេរ** *ន. របង; ព.ជ.៖* ងគារ។

**មពេស** *កិ. ប្រោស។*

**មពែត** *កិ. រឹតគាប ,។*

**មពែរ** *ន. ស្ទឹកឈើដែលគេយកមកផ្ចុំធ្វើជាសំឡេងសត្វ;* ***ឧទា.*** **អោសមពែរជានញហ្យាង់កិនជឹល ។** *ផ្ចុំស្ទឹកឈើធ្វើជាសំឡេងកូនឈ្លូស។*

**មពែស** *ន. ទិស, ខាង។*

**មពៃ** *គុ. ផ្អែតផ្អន់, ណាយ;* ***ឧទា.*** **មពៃញេត មពៃឆោង ។** *ផឹកស៊ីផ្អែតផ្អន់។*

**មពោ** *កិ. តម។*

**មពោង** *ន. ទ្វារ។*

**មពោងងគារ** *ក្លោងទ្វាររបង;*
*ព.ដ.៖* មពោងមពេ។

**មពោងឆិង់** *ក្លោងទ្វា;* ***ឧទា.*** **មពោងឆិង់ជែ ។** *ក្លោងទ្វាផ្ទះ។*

**មពោងមពេរ** *ក្លោងទ្វាររបង;*
*ព.ដ.៖* មពោងងគារ។

**មពោងលិស** *បង្អួច;*
*ព.ដ.៖* មពោងម្ហិស។

**មពោងម្ហិស** *បង្អួច;*
*ព.ដ.៖* មពោងលិស។

**មពោច** *ន. ទ្រនិច។*

**មពោន** *កិ. លាក់។*

**មពោមពា** *ន. សត្វចតុប្បាទ។*

**មពោយ** *ន. ពំនូកសំរាម។*

**មពោល** *ន. ពួក, ក្រុម។*

**ទូមពោល** *មួយក្រុម, មួយពួក។*

**មពោលផ្ទូងច្រិស** *គ្រិស្តបរិស័ទ, អ្នកជឿ។*

**មពោស** *ន. ឆ្នាំទី២, ៣ និងទី៤ នៃចម្ការដែលបានកាប់រួចរាល់;* ***ឧទា.*** **មីរមពោស ។** *ចម្ការឆ្នាំទី២/៣/៤។*

**មពោះ** *ឈ. តែ;* ***ឧទា.*** **រាពាយមោគែសរែកជាកើតម្ចូ មពោះមាគែសជារាលៅម្ចូ ។** *ទន្សាយមិនបានច្រូតស្រូវដូចគេ តែវាមានច្រើនជាងគេ។*

**មពិត** *ន. កន្ទុយព្រួញ, ស្ទាបព្រួញ។*

**មពិត់** *កិ. រើ, កម្រើក;* ***ឧទា.*** **កាសគឹតឆាក់មពិត់ជិង់តី ។** *វាដឹងខ្លួនកម្រើកដៃជើង។* ***ឧទា.*** **កាមពិត់តែសនទារ ។** *ត្រីរើទាំងជាប់សន្ទូច។*

**មពិត់ញូឆ្លិង់ញូឆ្លាង់** *រើបម្រះ។*

**មពិរ** *ន. ធ្មត។*

**មពិស១** *កិ. លោតឡើង។*

**មពិសចីប** *លោតឡើងយ៉ាងរហ័ស។*

**មពិសច្រឹប** *លោតឡើងយ៉ាងរហ័ស។*

**មពិសដើប** *លោតឡើង។*

**មពិសទិត់** *លោតឡើង (ទិត់)។*

**មពិស**$_{២}$ *កិ. អុជ*; ព.ដ.៖ មពួច។

**មពិស**$_{៣}$ **ន.** *ឧបករណ៍ធ្វើពីខ្សែសម្រាប់ដេញចាប។*

**មព្យាច់** (ព.ក្វ.៖ ព្យាច់) **កិ.** *ធ្វើសរសៃ, គក់ប្របាច់។*

**មព្យាត់** ន. *អណ្តាត។*

**មព្រាង** *កិ. ធ្វើយញ្ញបូជា*; **ឧទា. ឆិះពែមងខឹតមព្រាង ។** *យកពពែមកសម្រាប់ធ្វើយញ្ញបូជា ។*

**មព្រាត** *កិ.វិ. រូ*; មើល៖ ខោម, ឆ្យាល។

**មព្រាន់** ន. *ឈ្មោះដើមឈើម្យ៉ាង។*

**មព្រាស** *កិ. បោកទម្លាក់។*

**មព្រឹង** *កិ. ពាក្យកាព្យ, កំណាព្យ*; **ឧទា. មែមព្រឹងនាវអិន់គិប់អ្យាត់** *សូមអ្នកសូត្រកំណាព្យឱ្យខ្ញុំស្តាប់។*

**មព្រឹតមព្រើ** *កិ. ច្រៀងចម្រៀង។*

**មព្រើ** *កិ. ច្រៀង។*

**មព្រើងគិត់** *ច្រៀងមិនឈប់ឈរ។*

**មព្រើស** *កិ. បណ្តេញ។*

**មព្រោន** *គុ. ជ្រួញ, រួញ*; **ឧទា. អាវមព្រោន ។** *អាវជ្រួញ។*

**មព្រិប** *កិ. ផ្អប*; **ឧទា. មព្រិបតីមាតើមត្លែ ។** *ផ្អបដៃនឹងឫស្សី។*

**មព្រិម់** *កិ. ញញ័រ, ញ័រ*; **ឧទា. មព្រិម់នុយ្យនហិម់ ។** *ញ័របេះដូង។*

**មព្លាស** *កិ. ស៊ី, ប្រាស (ពាក្យមើលងាយ)។*

**មព្លី** *កិ. ជូនវិញ។*

**មព្លឺ** *កិ. ល្បួង, បញ្ឆោត, 'ព្រែស';* ព.ដ.គ្រ.៖ នទើម *'ព្នុរ'*។

**មព្លុង** *កិ. ទម្លាយ*; **ឧទា. លាប់អុចមាមព្លុងមពោងរ ។** *ចង់ចូលទម្លាយទ្វាតែម្តង។*

**មព្លុន** *កិ.វិ. ពាក្យបង្ហាញពីអាការៈងក់ក្បាលយល់ព្រម*; មើល៖ ងគុស។

**មព្លួម** *កិ. នាំរឿងនាំហេតុ*; ព.ដ.៖ គុចពុរ។

**មព្លោញ** ន. *ស្រួច។*

**មព្លោញលាវើល** *ស្រួចរលែម។*

**មរា** ន. *នឹង*; ព.ដ.៖ ទឹង, តែ។

**មរាច់** ន. *ម្ទេស។*

**មរិច** ន. *ម្រេច។*

**មរេស** *កិ. ប៉ប្រិច។*

**មរ៉ែ** (*ព.ក្ង.៖* មែរ៉ែ) **សព្វ.** *របស់, កម្មសិទ្ធិ (ប្រើចំពោះបុរស); មើលៈ រ៉ែ។*

**មរ៉ៃវ** *ន. អាប។*

**មរោ** *ន. លេខ។*

**មរោស** *កិ. កុហក, ភូតភរ; ព.ជ.៖* ឆឺរ។

**មរ៉ឹង** *ន. សត្វស្វាបមួយប្រភេទ។*

**មរ៉មរាង** *កិ.វិ. រហូតអស់កល្ប, ជានិច្ចកាល, ជានិរន្តរ៍, 'ព្រៃស'; ព.ជ.គ្រ.៖* នហិរិ *'ព្នុរ'។*

**មលាង់** *ន. ស្ទឹកគ្រៃ;* **ឧទា. មមុមមលាង់ ។** *គល់ស្ទឹកគ្រៃ។*

**មលាង់ហូ** *ស្ទឹកគ្រៃមួយប្រភេទមានគល់ និងស្ទឹកពណ៌ក្រហមចាស់។*

**មលី** *ន. សំឡី។*

**មលីក** *ន. ស្នា, 'ព្នុរ'; ព.ជ.គ្រ.៖* មម្លឹក *'ព្រៃស'។*

**មលូ**១ *ន.* ១) *ម្ទូ;*២) *ក្ដៅ។*

**មលូ**២ *កិ. លូ;* **ឧទា. ឆិមលូ ។** *ឆ្កែលូ។*

**មលូកឹត** *ន. ក្រសាំងទាប។*

**មលែស** *គុ. សុភាព, ស្លូតបូត, ចិត្តសុភាព, ទន់ភ្លន់។*

**មលៃ** *ន. សាច់សុទ្ធ។*

**មលៃ** *ន. សាច់សុទ្ធ; មើលៈ* នពោ, នពឹង។

**មលៃពាត់** *សាច់ដុំ។*

**មលោ** *ន. ក្ដៅមាន់។*

**មលិ**១ *គុ. គ;* **ឧទា. មូនុយ្សមលិ ។** *មនុស្សគ។*

**មលិ**២ *ន. ជញ្ជ្រាំង;* **ឧទា. មលិមពានទ្រោកភាពូ ។** *ជញ្ជ្រាំងជាចំណីគោក្របី។*

**មលិ**៣ *ន. ទន្ទាប់។*

**មលិម់**១ *គុ. មូល;* **ឧទា. រាព្លៃនៃសមលិម់កើតព្លៃក្រិច ។** *ផែនដីមានរាងមូលដូចផ្លែក្រូច។*

**មលិម់**២ *ន. ពាក្យប្រើសម្រាប់រាប់ចំនួន, ដូច "អ៊ឹ";* **ឧទា. មមិទូមលិម់ ។** *ពោតមួយផ្លែ។*

**មលិស** (*ព.ក្ង.៖*អោមអូរ) **កិ.** *ដណ្ដឹង, ស្ដីដណ្ដឹង។ ព្នុរ ព.ជ.គ្រ.៖* ងកិល *'ព្រៃស'។*

**មមាក់** *កិ. រែក។* **ឧទា. មមាក់ទាកមារថុង ។** *រែកទឹកពីរប៉ោត។*

**មមោង** *កិ. វាយ*; ***ឧទា.*** **នើមគុច នទ្រោកពាង់ឆិះរានាយមមោងតា មោកនទ្រោក ។** *អ្នកកាប់គោ គាត់យកអង្រែវាយក្បាលគោ។*
*ពុរ;*
*ព.ជ.គ្រ.៖* ទិរ *ណាង។*

**មមាត់**១ *កិ.វិ. គ្រាន់តែ។*

**មមាត់**២ *ន. កម្បង់*; ***ឧទា.*** **គិប់ក្វាកផៃ ទូមមាត់ ។** *ខ្ញុំកើបអង្ករមួយ កម្បង់។*

**មមាន** *កិ. រើស*; ***ឧទា.*** **គិប់មមាន ឆាញ្យាង់ម្ងូមអារ់ ។** *ខ្ញុំរើសបាយ តាមផ្លូវដែលគេបោះចោលមក ហូប។*

**មមាន់** *កិ. ស្មៀក (សំពត់)*; *មើល៖* ញឆិស។

**មមាស**១ *ន. ចម្លាម, ប្រគាប*; ***ឧទា.*** **មមាសតើមឆី ។** *ចម្លាមឈើ ឬ ប្រគាបឈើ។*

**មមាស**២ *កិ.* ១) *សំពះ*, ២) *គាល់*; ***ឧទា.*** **គិប់ហាន់មមាសកាដាច់ ។** *ខ្ញុំទៅគាល់ស្ដេច។*

**មមាស**៣ *ន. កាំ*; ***ឧទា.*** **មមាសគួង ។** *កាំ ជណ្ដើរ។*

**មមាស**៤ *សព្វ. ឯណា?, កន្លែងណា?*

**មមិចមមើយ** *កិ. ស្រមើស្រមៃ។*

**មមឹង** *ន. ផ្កាយព្រឹក។*

**មមឹត** *កិ. រំអួយ*; ***ឧទា.*** **កិនឆៃតើញ មមឹត នោកមូនទើយ ។** *ក្មេងចាប់រំអួយ នៅពេលគេ ចំអន់។*

**មមឹ** *ន. ឪពុក*; *ព.ជ.៖* មឹ។
**មមឹចោង** *ឪពុកចុង*; *ព.ជ.៖* មមឹយោង។
**មមឹតើម** *ឪពុកដើម, ឪពុកបង្កើត។*
**មមឹពិ** *ឪពុកក្មេក។*

**មមឹរ** *គុ. រអិល*; ***ឧទា.*** **ត្រិងមមឹរ នោកច្រើមឹស ។** *ផ្លូវរអិល ពេល មេឃភ្លៀង*

**មមឹប** *កិ.វិ. អក*; *មើល៖* ឆា។

**មមុក** *កិ. ជ្រមុជ*; ***ឧទា.*** **មមុកនោងអា ទាកតែមេង ។** *ជ្រមុជឃ្លោកក្នុង ទឹកដើម្បីឱ្យពេញ។*

**មមុង** *ន. សំយាប។*

**មមុច** *ន.* ១) *ក្រុមតូច*, ២) *រមូរ*; ***ឧទា.*** **មមុចច្រាយ ។** *អំបោះមួយរមូរ។* ៣) *គំនរ*; ***ឧទា.*** **លិងទូមមុច ។** *ឧសមួយគំនរ។*
*ព.ជ.៖* មមូន។

**មមុត** ន. *ពន្ទក។*

**មមុម** ន. *គល់;* **ឧទា. មមុម មលាង់ ។** *គល់ស្ទឹកក្រៃ។*

**មមុរ** កិ. *ស្ពាយ, ក្រវាត់ចង្កេះ។*

**មមុស** ន. ១) *ពពុះ;* **ឧទា. មមុស ឆាបូ ។** *ពពុះសាប៊ូ។*
២) *កម្ទេច;* **ឧទា. មមុស នទ្រូយ្យ ។** *កម្ទេចរណារ ឬ អាចម៍កន្ទង់ ឬ អាចម៍រណារ។*

**មមូ** *សព្វ. អ្នកណា?, នរណា?*
**មមូមិស** *អ្នកណា?, នរណា?*
*'ព្រែស';ព.ដ.គ្រ.៖* មូមិស *'ព្នារ'។*

**មមូង** ន. *មាត់។*
**មមូងមញ្លោញ** *ចំពុះ។*

**មមូន** ន. *គំនរ;* **ឧទា. រាហៃទូមមូន ។** *ចំបើងមួយគំនរ។*
*ព.ដ.៖* មមុច។

**មមើត** កិ. *ហុច។*

**មមើម** គុ. *គួរសម, ល្មម, គ្រប់គ្រាន់;* **ឧទា. អ្វែសមមើម ។** *ល្អគួរសម។*

**មមើយ** កិ. *យល់សប្តិ, សុបិន្ត។*

**មមើស** កិ. *ប្រាប់។*
**មមើសរើម** *អធិស្ឋាន។*

**មមេង** កិ. *បំពេញ។*

**មមេន** ន. *ទីសម្គាល់;* **ឧទា. មមេន អិន់បនលានតឹតលិរ ។** *ទីសម្គាល់ឱ្យអ្នកភូមិដឹងមុន។*

**មមេល** ន. *កន្ទេល។*

**មម៉ែ** កិ. *ពឹង;* **ឧទា. គិប់មម៉ែមៃ ។** *ខ្ញុំពឹងអ្នក; ព.ស្រ.៖* នទែ។
**មម៉ែមមិត** *ពឹងពាក់។*

**មម៉ែស** គុ. *កំណាញ់;* **ឧទា. ពាង់ មូនុយ្យមម៉ែស ។** *គាត់ជាមនុស្សកំណាញ់។*

**មម៉េះ** គុ. *ទទឹក;*
*ព.ដ.៖* ឆុស, ម៉េះ។

**មមោល** កិ. *ប៉ះ;* **ឧទា. គិប់មមោល ខិអារ ។** *ខ្ញុំប៉ះខោអាវ។*

**មមិ** ន. *ពោត។*

**មមិប់** កិ.វិ. *ថ្កឹង។*

**មមិរ** ន. *រង;* **ឧទា. មមិរឆាពៃ** *រងស្ពៃ។*

**មមិល់** គុ. *ក្រាស់;* **ឧទា. កាជារអ្យា មមិល់ងាន់ ។** *ក្តារនេះក្រាស់ណាស់។*

**មម្រា** គុ. *ស្គូវ។*

**មម្រោច** *កិ. ពង្រាយ;* ***ឧទា.*** **កិនឆៃ**
**មម្រោចនទិក់ ។** *ក្មេងពង្រាយសំរាម។*

**មម្រោម** *កិ. សម្ងុត។*

**មម្រិចមម្រោច** *កិ.វិ. វគាត់វគាយ,*
*ពាសវាលពាសកាល។*

**មម្រើង** *ន. ស្វៃ។*
**មម្រើងទាក** *ក្អែលទឹក។*

**មម្រួយ** *ន. សក់ពោត។*

**មម្រើយ** *កិ.វិ. យឺត។ឧទា.* **យៅហាន់**
**មម្រើយៗ ។** *ខ្លាដើរយឺតៗ។*

**មម្រេស** *គុ. ផៅ។*

**មម្រែស** *កិ. គ្រហែម។*

**មម្រែះមម្រើយ** *កិ.វិ. បង្អែបផ្អង់។*

**មម្លាង** *កិ. បកប្រែ;*
*ព.ដ.៖* **រាម្លាង។**

**មម្លឹក** *ន. ស្នា, ព្រៃស;*
*ព.ដ.គ្រ.៖* **មលឹក** *ត្នុរ។*

**មម្លុ** *គុ. ល្វេល្វើ, ភ្វីភ្វើ;*
*ព.ដ.៖* **រាហិង់។**

**មម្លេង** *កិ. សាត់អណ្តែត, សាត់ព្រាត់;*
*ឧទា.* **ហាន់មម្លេង ។** *ដើរសាត់*
*អណ្តែត។*

**មម្លៃ** *ន. ស្វាយព្រៃ, ត្នុរ;*
*ព.ដ.គ្រ.៖* **ងលៃ** *ញ៉ាត់;*
**ងគ្លៃ** *ណាង៍។*

**មម្លែល** *កិ.វិ. គាំង; មើល៖* **ខាន។**

**មម្ហ៊ិ** *កិ. បំពាក់ (ក្រវិល);* ***ឧទា.*** **មម្ហ៊ិ**
**មម្ហ៊ិតោរ ។** *បំពាក់ក្រវិល។*

**មម្ហ៊ិតោរ₁** *ន. ក្រវិល។*

**មម្ហ៊ិតោរ₂** *ន. កង្កិច។*

**មម្វាច់** *គុ. កំព្រា, ឯកា, ឯកោ;* ***ឧទា.***
**អ្យារ់មម្វាច់ ។** *មាន់កំព្រា។*

**មម្វាត់** *ន. ឧបករណ៍ក្មេងមួយបែបធ្វើ*
*ពីឃ្មោក។*

**មហាម** *ន. ឈាម។*

**មហឹក** *គុ. អាក្រក់, គម្រក់។*
**មហឹកម្លែម** *ស្មោកគ្រោក។*

**មហឹង** *កិ. លាប;*
*ព.ដ.៖* **ហឹង, រាឆ្វូត។**

**មហុង** *ន. ល្ហុង, ត្នុរ;*
*ព.ដ.គ្រ.៖* **តាលិង** *៉ាអូង៍។*

**មហូ₁** *ន. ផុយ; ព.ដ.៖* **នអើច។**

**មហូ₂** *គុ. ទន់;*
*ព.ដ.៖* **រាទឹ, រាមាន់។**

**មហៃ** *គុ. ១) ថ្មី,*
*– កិ.វិ. ២) ថ្មីៗ នេះ។*

**មហៃ** *ន. ស្មឹ។*

**ត្រាវនហាមហៃ** *បន្ទៃស្ទឹកស្មឹ។*

**មហិក** *ន. ក្ដាមឈូសមួយបែបធ្វើអំពីសម្បកឈើ។*

**មហិត់** *ន.* ១) *ថ្នាំជក់,* ២) *បារី។*

**មហិប** *ន. ល័ក្ដ។*

**មអា** *គិ.វិ. ឥឡូវ។*

**មអារី** *ឥឡូវនេះ។*

**មអាក** *គុ. សប្បាយ, រីករាយ។*

**មអាកមពៃ** *សប្បាយឆ្អែតឆ្អន់។*

**មអាក់** *គិ. ព្យួរ។*

**មអារ់** *គិ. ចោល, បោះចោល;*

*ព.ដ.៖* ជាង់។

**មអារ់ខ្ទាប់** *ចោល(ខ្ទាប់)ជាសំឡេងចោល។*

**មអារ់ប៉្ញរ់** *ចោលវឹ។*

**មអារ់ព្រុង** *ចោលប្រាវ។*

**មអីន** *គិ. ពិត។*

**មអឹ** *គិ. ខ្ចើម។*

**មអឹម** *គិ. ក្អួតចង្អោរ។*

**មអុយ** *សព្វ. អ្នកពល់គ្នា, 'ណាង';*

*ព.ដ.គ្រ.៖* ខាន់មៃ *'ព្នុរ'។*

**មអូម** *ន.* ១) *ស្នឹម,* ២) *ពាក្យជេរ* (មនុស្សស្រី)។

**មអាក់មអូម** *ឧ. ពាក្យជេរ;*

*មើល៖* ខាយមអាក់ខាយមអូម។

**មអួយ** *គិ.វិ. ប្រហែល។*

**មអើក** *គិ. លែង, ដោះលែង;*

*ព.ដ.៖* បើក។

**មអេត** *ន. ដំណើប។*

**មអែប** *ន. ចង្អែក។*

**មអោ** *ន. ទោម;* ***ឧទា.*** **នាវជិងទូមអោ ។** *ប្រវែង ១ ទោម។*

**មអិង់**₁ *គិ. ប្រុង;* ***ឧទា.*** **មអិង់មាហាន់ ។** *ប្រុងនឹងទៅ។*

**មអិង់**₂ *គិ. តម្រង់;* ***ឧទា.*** **មអិង់មីក្រោឆិង់បិនមិន់ ។** *តម្រង់មេក្រូចំភូមិយើង។* *ព.ដ.៖* នត្រិង់។

**មអិន់ញជ្រិះ** *គិ. ឌឹដង;*

***ឧទា.*** **មអិន់ពាង់ញជ្រិះ ។**

*មិនបាច់ឌឹដងអ្វីទេ។*

*ព.ដ.៖* មអិនរាលើន។

**មា**₁ *ន. ស្គាំ; ព.ផ្ទ.៖* ចៀ។

**មា**₂ *ធ. ដើម្បី, សម្រាប់;*

***ឧទា.*** **គិប់រាវាត់មោតោមាញចិ ។**

*ខ្ញុំទិញម៉ូតូ (សម្រាប់/ដើម្បី) ជិះ។*

*មើល៖* តែមា។

**មា៣** *ផ. ប្រើសម្រាប់រាប់លេខចាប់ពី ១១ ឡើងទៅ (ជីតមាម្វាយ)។*

**មា៤** *ផ. នឹង;* ***ឧទា*** **.នទ្រែលមា ។** *ជាមួយនឹង។*

**មា៥** *ផ. ទៅកាន់;* ***ឧទា.*** **មមើស មាពាង់... ។** *ប្រាប់ទៅគាត់។*

**មា៦** *ផ. នូវ;* ***ឧទា.*** **ហែទាន់មូកើលមានទើអាប់នតីលអីហែមោហិៈ តែស ។** *សុំនូវអ្វីដែលយើងកំពុងខ្វះខាត។*

**មាង** **ន.** *កណ្ដឹង។*

**មាង់** (*ព.ក្ល.៖* នាង់) **ន.** *យប់;* ***ឧទា.*** **មាង់មិចអាងកាស ។** *ដេកពីព្រលប់ ភ្ញាក់ពីព្រលឹម។*

**ទូនាង់រាអាង** *មួយយប់ទល់ភ្លឺ។*

**មាង់តាអិយ** *យប់នេះ។*

**មាង់តិ** *យប់ម្សិល។*

**មាង់នើស** *យប់មិញ។*

**មាង់ៗ** *យប់ៗ។*

**ក្លិងមាង់** *កណ្ដាលអធ្រាត្រ;* *ព.ដ.៖* ងគូលមាង់។

**មាង់កាល់តី** **ន.** *ត្រីយម្ខាង។*

**មាច់** **ន.** *មូស។*

**មាឆឹន** (*ខ្ចីពី៖ ខ.*) **ន.** *ម៉ាស៊ីន។*

**មាឆឹនកិសឆី** *ម៉ាស៊ីនអារឈើ។*

**មាឆឹនឆុសឆី** *ម៉ាស៊ីនឈូសឈើ។*

**មាញ** *កិ. ខ្ចី។*

**មាញ់** **ន.** *ផ្កាយ។*

**មាត់** **ន.** *ក្អែក។*

**មាត់នារ** **ន.** *ព្រះអាទិត្យ។*

**មានមា** *កិ.វិ. គ្រាន់តែ។*

**មានា** (*ខ្ចីពី៖ ខ.*) **ន.** *ម៉ាណា។*

**មាយ្យ១** **ន.** *អៀន;* ***ឧទា.*** **កិនឆៃតែស មាយ្យ ។** *កូនក្មេងកើតអៀន។*

**មាយ្យ២** **ន.** *មាស។*

**មារ១** **ន.** *ផ្ចឹ (ឈើមួយប្រភេទមានខ្លឹមនិងត្រូវយអាចធ្វើអន្ទក់បាន)។*

**មារ២** **ន.** *ឧបករណ៍នេសាទត្រីម្យ៉ាង។*

**មាឈារីន** (*ខ្ចីពី៖ ខ.*) **ន.** *ម៉ាឡារីន (ថ្នាំគ្រុនចាញ់)។*

**មាៈមា** ***សព្វ.*** *នឹងអ្វី, បានអ្វី។*

**មី** **ន.** *សាច់ថ្លៃ, បងថ្លៃ, ប្អូនថ្លៃ, កូនប្រសា;* ***ឧទា.*** **អីមីពាង់លោសអាមីរ ។** *បងថ្លៃរបស់គាត់ទៅចម្ការ។*

*ព.ស្រ.៖* ក្លៃ;

*ព.ស្រ.៖* បាន់។

**មីរ** **ន.** *ចម្ការ។*

**មីរឆាវ** *ព្រៃ ឬ ចម្ការចាស់ដែលគេទុកចោល ។*

**មីរនទ្រីស** *ចម្ការថ្មី;* *ព.ក្ង.៖* មីរមពុយរ្យ។

**មីរមពោស** *ចម្ការចាស់ (ពីឆ្នាំទីពីរដល់ឆ្នាំទីបី)។*

**មីរមពោសមម្លេះមម្លាះ** *ចម្ការចាស់។*

**មីរមពោសម្លេះម្លាះ** *ចម្ការចាស់ (ពីឆ្នាំទីបួនដល់ឆ្នាំទីប្រាំមួយ)។*

**មីរមា** *ស្រែចម្ការ។*

**មីស** *ន. ភ្លៀង;* **ឧទា. មីសឆា ។** *ទទឹកភ្លៀង។*

**មីសខូក** *ភ្លៀងឈូ។*

**មឹត១** *គុ. ក្តីប។*

**មឹត២** *កិ. ចិញ្ចឹម, 'ព្នរ';* *ព.ដ.គ្រ.៖* មិត់ *'ព្យ៉ាត់'។*

**មឹតអ្វាញ់** *ថែរក្សា, ទទួលខុសត្រូវ;* **ឧទា. មែមឹតអ្វាញ់កនឆែ ។** *អ្នកថែរក្សាកូនក្មេង។ 'ព្នរ';* *ព.ដ.គ្រ.៖* មិត់អ្វាញ់ *'ព្យ៉ាត់'។*

**មឹត៣** (*ខ្ចីពី៖ ខ.*) **ន.** *មិត្ត។*

**មឹតជាង់** *មិត្តភក្តិ។*

**មឹន** *កិ. គិត, 'ព្នរ';* *ព.ដ.គ្រ.៖* ងក្លិន់ *'ព្យ៉ាត់'។*

**មឹនញហ្វាច** *នឹកស្តាយ។*

**មឹនអាងឹរ** *នឹក, គិតមើល, នឹកគិត។*

**មឹល** *ន. អម្ពិល។*

**តើមមឹល** *ដើមអម្ពិល។*

**មឹច** *កិ. មើលងាយ។*

**តើមមឹច** *សើចចំអក។*

**មឹចញឆិត** *បន្ទាបបន្ថោក។*

**មឹចមាច** *ឆ្មើងឆ្មៃ។*

**មឹចរាមិត** *តិះដៀល, ដៀលត្មះ។*

**មឹន** *កិ. ដួល;* **ឧទា. តិប់មឹនម្ងូតែមាតាម់ម្ងូមតាមីរតិប់ ។** *ខ្ញុំដួលពួកគេឱ្យដាំដំឡូងនៅចម្ការខ្ញុំ។*

**មឹរ** *កិ. ក្ងួតករ។*

**មុង** (*ខ្ចីពី៖ ខ.*) **ន.** *មុង។*

**មុងមាង** *ន. កន្ទេះឡង់។*

**មុត** *កិ. ចូល, 'ណាង';* *ព.ដ.គ្រ.៖* លាប់ *'ព្នរ'។*

**មុន** *ន. មុន។*

**មុនតី** (*ខ្ចីពី៖ ខ.*) **ន.** *មន្ទីរ។*

**មុយ្យ** *កិ. ត្រាយ។*

**មុរ** *កិ. ជ្រមុជ;* *ព.ដ.៖* ងិរ។

**មុល** *ន. ក្បាលទឹក (ឃ្មុំ)។*

**មុលឆុត** *ក្បាលទឹកឃ្មុំ។*

**មុស** (*ព.ក្ង.៖*មោស) **ន.** ១) *ប្រមុះ*; ***ឧទា.*** **មោជេងលាមមុសលាមមាត់ អ្វាញ់ ។** *មើលទៅវាមិនពេញ ភ្នែក។* ***ឧទា.*** **ទីមុសទីមាត់ ។** *ពេញចិត្ត។*២) *សម្បោរ។*

**ព្រោមមុស** *ប្រមុះ។*

**មុសមាត់** *មុខ។*

**ហិរមុស** *ហៀរសម្បោរ។*

**មូច** ***កិ.*** *មុជ។*

**មូញ** ***កិ.*** *ច្រៀង*; *ព.ជ.៖* មព្រើ។

**មូត** ***ន.*** *ទីងមោង។*

**មើ** ***ឈ.*** *ទាល់តែ...ទើប...*;

***ឧទា.*** **ជាននអាមើអ្វេស ។** *ធ្វើអញ្ចឹងទើបល្អ។*

**មើង** ***កិ.*** ១) *ញៀន*; ***ឧទា.*** **លើយញេតនទ្រាញ់ក្លាចលាសមើង ។** *កុំផឹកស្រាក្រែងលោញៀន។* ២) *ធ្លាប់*; ***ឧទា.*** **លើយអិន់ព្រាក់អិក់អីរ ពាង់មើង ។** *កុំឱ្យលុយច្រើនពេក វាធ្លាប់។*

**មើញ** ***កិ.វិ.*** *ចង់តែ*; ***ឧទា.*** **មើញមាឆា ។** *ចង់តែហូប។*

**មើតមើរ** ***កិ.វិ.*** *តែលតោល*; ***ឧទា.*** **គុទូហៃអេងមើតមើរ ។** *នៅម្នាក់ឯងតែលតោល។*

**មើម** **ន.** ១) *ម៉េច?*, *របៀបណា?* ***ឧទា.*** **មើមបើករាពូមៃទឹងអិន់ឆាមាគិប់?** *តើអ្នកលែងក្របីយ៉ាងម៉េចបានជាស៊ីស្រូវរបស់ខ្ញុំ?* ២) *តើ...?* ***ឧទា.*** **មើមមៃតាយទើយហាវតើមព្លៃអ្យាជិង់?** *តើតាយអាចឡើងដើមនេះបានដែរឬ?*

**មៀន** (*ខ្ញីពីះ ខ.*) **ន.** *មៀន។*

**ព្លៃមៀន** *ផ្លៃមៀន។*

**មេ** ***ឧ.*** ពាក្យប្រើខាងចុងឃ្លា (ចំពោះមនុស្សប្រុស); *ព.ជ.៖* មេះ ។

**មេត** ***កិ.*** *ក្រឡេកមើល។*

**មេតអ្វាញ់** *ពិនិត្យមើល។*

**មេម** ***កិ.*** *បិទមាត់*; ***ឧទា.*** **មេមមម្ងងលើយងើយ ។** *បិទមាត់កុំនិយាយ។*

**មេះ**₁ **ន.** *ម្ដាយ*, *ម៉ែ*, *មាតា* (*ពាក្យល្អ*); *ព.ស្រ.៖* មែ។

**មេះចោង** *ម្ដាយចុង។*

**មេះតើម** *ម្ដាយដើម*, *ម្ដាយបង្កើត។*

**មេះពិ** *ម្ដាយក្មេក។*

**មេះមបឺ** (*ព.ក្ង.៖* មេះបឺ; មែមបឺ) *ឪពុកម្ដាយ។*

**មេះ**₂ *ឧ.* ពាក្យប្រើខាងចុងឃ្លា (ចំពោះមនុស្សប្រុស);
*ព.ដ.៖* មេ ។

**មែ** *ន.* ១) ញី (*សម្រាប់សត្វញី*), ២) *មេ។*

**មែក្លឹង** *មេកណ្ដៀរ, ស្ដេចកណ្ដៀរ។*

**មែង** *ន. ក្បែរ។*

**មែងទាក** *ក្បែរទឹក (អូរ)។*

**មែត** (*ខ្ចីពីៈ បារ.*) **ន.** ១) *ម៉ែត្រ,* ២) *ម៉ែត្រវាស់។*

**មែន**₁ *ន. មៀន;* **ឧទា. មែនពេស ។** *មៀនកាំបិត។*

**មែន**₂ *គុ. ក្រិន;* **ឧទា. មែនតីមែនជិង់ ។** *ក្រិនដៃក្រិនជើង។*

**មែវ** *ន. ឆ្មា។*

**មែស** *ន. សសរ។*

**មែសតិង់** *សសរផ្ទះដែលគ្រោងរួចហើយ។*

**មែសនទាល់មុត** *សសរជើងរៀង។*

**មែសមឹរ** *ស៊ិយ។*

**មែ** *សព្វ. អ្នក, ឯង, លោក។*
*ព.ដ.គ.៖* បែ។

**មោ**₁ *កិ.វិ. អត់,* មិន; *ព្នុរ;*
*ព.ដ.គ្រ.៖* ប៊ី *ណាង;*
*ព.ដ.៖* លិច *ព្យ៉ាត់។*

**មោកាះ** *មិនរអែង។*

**មោខាច់** *មិនបាច់។*

**មោទើន** *មិនតែប៉ុណ្ណោះ។*

**មោនាន់** *មិនទាន់ (ដោយសារលឿនពេក ឬ ប្រញាប់ពេក);*
*ព.ដ.៖*មោហិៈ, អែនាន់, អែហិៈ។

**មោនាៈ** *មិនសូវ;*
*ព.ដ.៖* មោលាង់, មោអឺរ។

**មោនី** *មិនខ្វះទេ។*

**មោលាង់** *មិនសូវ;*
*ព.ដ.៖* មោនាៈ, មោអឺរ។

**មោហិៈ** *មិនទាន់ (ធ្វើមិនទាន់ហើយ); ព.ដ.៖* មោនាន់, អែនាន់, អែហិៈ។

**មោ**₂ **ន.** *ថ្មដែកកេះ។*

**មោក** **ន.** *មួក។*

**មោច** **ន.** *ផ្ទូរ។*

**មោតោ** (*ខ្ចីពីៈ ខ.*) **ន.** *ម៉ូតូ។*

**មោយ** *គុ. ម៉ដ្ដ;* **ឧទា. ចិយ្យមោយ ។** *ខ្សាច់ម៉ដ្ដ។*
*មើលៈ* រាហេន, រាហេស។

**មោរ** *គុ. ហើម។*

**មោលាស** *ឈ. ឫ។*

**មោរ្យាង់** *កិ.* ១) *ស្រងេះស្រងោច,* ២) *នឹក។*

**មោះ** *កិ.វិ. បានតែ;* *ឧទា.* **ពាង់មោះ មាងើយទើម ពាង់នើមមោជាន ដិង់ ។** *គាត់បានតែនិយាយតែ មិនធ្វើ។*

**មិ** *កិ. លាក់ (រឿងសម្ងាត់);* *ឧទា.* **មិសមិពាង់តៃ ។** *ខ្ញុំមិនលាក់លៀមទេ...។* *ពា.ដ.៖* ពោន; *មើល៖* មផារ។

**មិង**១ *ន. មង (ដាក់ត្រី)។*

**មិង**២ *ន.* ១) *ម៉ោង, ពេលវេលា,* ២) *នាឡិកា។*

**មិង់** *ន. រំពាត់, ដំបង។*

**មិង់ច្រាយ្យ** *រនាស់ដៃ។*

**មិង់ជ្រា** *ឈើច្រត់។*

**មិង់មពេស** *អម្បោស។*

**មិង់រាព្លៃ** *ខ្សែតី។*

**មិង់រានាយ** *អង្រែ,ឈើជ្រួយបាយ។*

**មិត់** *កិ. ចិញ្ចឹម, 'ព្យ៉ាត់';* *ពា.ដ.គ្រ.៖* មឹត *'ព្នុរ'។*

**មិត់ញជ្រាង់** *ថែរក្សាការពារ។*

**មិត់តិន** *បន់;* *ឧទា.* **មិត់តិន ម្រាស ។** *បន់ព្រះ។*

**មិត់មើស** *ថែរក្សា។*

**មិត់មោក** *គ្រប់គ្រង។*

**មិត់អ្វាញ់** *មើលថែ, 'ព្យ៉ាត់';* *ពា.ដ.គ្រ.៖* ច្បាះអ្វាញ់ *'ព្រៃស'។*

**មិន**១ *ន. ក្មួយ (ស្រី, ប្រុស)។*

**មិន**២ *កិ. សួន, លញ់។*

**មិន់** *ន. ពុត;* *ពា.ស្រ.៖* នទ្រា។

**មុនតីពែត** (*ខ្ចីពី៖ ខ.*) *ន. មន្ទីរពេទ្យ។*

**មិប់** *កិ. ជួប។*

**មិម** *ន. វ័យ។*

**មិរ** *ន. មួរ;* *មើល៖* មា។

**មិល់** *គុ. ល្ងង់, 'ព្យ៉ាត់';* *ពា.ដ.គ្រ.៖* កាមិល់ *'វ៉ាអ្វង';* *ពា.ផ្ទ.៖* ម្លាវ។

**មិស**១ *កិ.វិ. ចេះ,ឆ្លាត (ប្រើចំពោះសត្វ);* *ឧទា.* **ឆិមែរ្យាមិសងាន់រំ ។** *ក្អែ នេះឆ្លាតណាស់។*

**មិស**២ *ឧ. អ្វី!* *ឧទា.* **អ្យាមិស!** *នេះនែ៎!* *ឧទា.* **មិសមៃ!** *មើល!* *ឧទា.* **តីនាតីមិស** *នោះនែ៎ស្អា* **តីមិស!** *នោះនែ៎!*

**មិស**₃ *ន.* ១) *ឈ្មោះ,*

– *កិ.* ២) *ដាក់ឈ្មោះ;* ***ឧទា.*** **ម្ទ្រៃទ្រាសអីមិសជីម្បារីនើស ។**

*នាងក្រមុំឈ្មោះព្យានោះ។*

**មិស**₄ *កិ.វិ.* *បាទ, ចាស៎ (ប្រើសម្រាប់ឆ្លើយតបនឹងសំណួរ ឬហៅ);*

*ព.ដ.៖* អើ, អឺ។

**មិស**₅ *សព្វ.* នុះ; *មើល៖* តីមិស។

**តីមិស** *នុះហ្នឹ៎ង។*

**មិស**₆ *សព្វ.* *ម៉េច?*

***ឧទា.*** **មិសលិចអាងាន់?**

*ម៉េចថាមិនមែន?*

**មិសកោះ** *ហេតុអ្វី?*

*ព.ដ.៖* មិសយិរ, មិសនាវ។

**មិសកិប់** *ចាំអ្វី?*

**មិសកិះ** *ខំធ្វើអ្វី?*

**មិសនទើ** *ស្អី?*

**មិសនាវ** *ហេតុអ្វី;*

*ព.ដ.៖* មិសកោះ, មិសយិរ។

**មិសបាះ** *អ្វីខ្លះ?* ***ឧទា.*** **មិសបាះនទើតាយពាង់គែសតាចួាញ?**

*នៅក្នុងផ្ទះរបស់បងតាយ តើមានរបស់អ្វីខ្លះ?*

**មិសយិរ** *មកពីអ្វី?, ហេតុអ្វី?* *ព.ដ.៖* មិសកោះ, មិសនាវ។

**មិសនតីល** *ឈ.* *ជាដើម;*

***ឧទា.*** **មិសនតីលចូជានមីរមា ។**

*គេធ្វើស្រែចម្ការជាដើម។*

**មិសលេងលាង** *ឈ.* មិនជម្មតាទេ។

**ម្យាង់** (*ព.ក្ង.៖* រាម្យាង់) *កិ.* *ស្ងួះពន្ទះ។*

**ម្យាត់** *កិ.* *លប;* ***ឧទា.*** **ម្យាត់រាអៀច ។**

*ដើរលបៗ។*

**ម្វាយ** *គុ.* *មួយ។*

**ម្វាយអឺ** (*ព.ក្ង.៖* មអឺ) មួយ (*គ្រឿង, ក្បាល, ម្នាក់*)។

# យ

**យា** *ន.* *អំប្រុស, អំស្រី,* *'ស្មៀង';*
*ព.ដ.គ្រ.៖* វា *'ព្នរ'*។

**យាង់** *ន.* *ពាង*។

**យាង់ត្រី** *ពាងមួយប្រភេទ*។

**យាង់ច្រុង** *ពាងមួយប្រភេទ* ។

**យាង់តាង់កែស** *ពាងមួយប្រភេទ*។

**យាង់នទ្រាង** *ពាងមួយប្រភេទ*។

**យាង់នទ្រុប** *ពាងមួយប្រភេទ*។

**យាង់មុស** *ពាងមួយប្រភេទ*។

**យាង់ភាល្វូង** *ពាងមួយប្រភេទ*។

**យាត** *កិ.* *ជន្ទ*។

**យារ** *កិ.* *យួរ*។

**យី** *ឧ.* *យី!*

**យឹស** *ឧ.* *សំឡេងភ្ញាក់*។

**យឺ** *ឧ.* *ណ៎ា!* ***ឧទា.*** **អែមាហាវពែះម្ហូ ឆ្យុមយឺ!** *សម្លាញ់ឯងជាអ្នកបេះណា!* *មើល៖* តែ។

**យឺត** *កិ.វិ.* *គិតតែ, បេះតែ*។

**យុ** *ន.* *ធ្នុក*។

**យុក** *កិ.* *ជ្រលក់*។

**យុង** *ន.* *ស្ពាន*។

**យុល** *ន.* *ស្នុក*។

**យួរ** *កិ.* ១) *បូម,* ២) *សម្រួត*។

**យើ** *ន.* *មីង*។

**យើក** *កិ.* *លើក*។

**យើង**$_{១}$ *ន.* *ក្ដាន់*។

**យើង**$_{២}$ *កិ.* *សម្រាំងទុកធ្វើពូជ;*
***ឧទា.*** **គាវ់ភាពុងអ្យា មាយើង នតឹល ។** *គ្រាប់ត្រសក់នេះសម្រាំងទុកធ្វើពូជ*។

**យើនមា** *ឈ.* *ប៉ុន្តែ,* *'ព្នរ';*
*ព.ដ.គ្រ.៖* ប្យាៈលាស *'ព្រៃស';*
*ព.ដ.៖* យើនលាស។

**យើនលាស** *ឈ.* *ប៉ុន្តែ;*
*ព.ដ.៖* យើនមា។

**យើរ** *កិ.* *លើកដៃ (ចុះចាញ់);*
*មើល៖* ញហើរ។

**យើស** *ឧ.* *ពាក្យឧទានឡើងដោយភ្ញាក់ផ្អើល;* ***ឧទា.***
**មាង់អាយើស ។** *យប់នេះហើយ*។

**យេ** *ឧ.* *យី!*

**យែស** *ន.* *ផ្កាក់,* *'រ៉ាអូង';*
*ព.ដ.គ្រ.៖* កាតុយ្យ, តុយ្យ *'ព្នរ'*។

**យោក** *ន.* *ភ្នំ*។

**យោកងគូ** (ព.ក្ង.៖ ងគូ) គល់ឈើ, 'ព្នុរ';
ព.ជ.គ្រ.៖ យោកងិល់ 'ព្យ៉ាត់'។
**យោកងិល់** (ព.ក្ង.៖ ងិល់) គល់ឈើ, 'ព្យ៉ាត់';
ព.ជ.គ្រ.៖ យោងគូ 'ព្នុរ'។
**យោកយាង** ព្រៃភ្នំ។
**យោកគ្លិង់** ន. កំប៉ោយ។
**យោង** កិ. ព្យួរ។
**យោងក្រើល** ព្យួរ (របស់ច្រើន)។
**យោងភាតើល** ព្យួរ(របស់តែមួយ)។
**យោងរឹប** ព្យួររឹប។
**យោងយាយ** ន. ទោង។
**យោន** ន. ជាតិកំណើត;
***ឧទា.* ឆឹតយោន ។** ចាប់ជាតិ។
**យោនយឺ** ន. ឈ្មោះបទភ្លេងជនជាតិព្នងម្យ៉ាង។
**យោម** ន. សាពយ, 'ព្យ៉ាត់';
ព.ជ.គ្រ.៖ ញោម 'ព្នុរ'។
**យោស** ន. បងស្រី, 'ព្នុរ';
ព.ជ.គ្រ.៖ រោស 'ណាង'។
**យោសក្លោ** បងស្រី និងប្អូនប្រុស;
មើល៖ អិសក្លោ។
**យោះ** កិ. អាណិត, 'ព្នុរ';
ព.ជ.គ្រ.៖ កាមាក 'រ៉ាអ្នង'។
**យោះយាច** អាណិតអាសូរ។
**យោះនអាច** អាណិតមេត្តា។
**យៅ** ន. ខ្លា; មើល៖ អូទុស។
**យៅនទ្រុំង** ខ្លារខិន។
**យៅមុរ** ខ្លាធំ។
**យៅម្រាច់** ខ្លាត្រី។
**យិង់** ធ. ទំនងជា។
**យិត** កិ. បាត់។
**យិតក្លាក់** បាត់ឈឹង។
**យិន់** ន. យួន។
**យិយ** ន. បបូរមាត់។
**យិរមា** ឈ. ដោយសារ។
**យិររី** ឈ. ហេតុនេះ។
**យិរលាស** ឈ. ពីព្រោះ, 'ព្នុរ';
ព.ជ.គ្រ.៖ ប្យាះលាស 'ព្រៅ'។
**យិរមើស** ឈ. មកពី, ដោយសារតែ។

# រ

**រាក** *កិ. ដេរ។*

**រាកញជុរ** *ដេរប្រទេច។*

**រាក់** *កិ. បម្រើ, ថែរក្សា;*

*ឧទា.* **ជេសរីតើសខិអាររាក់អិន់គិប់ឆោង ។** *បន្ទាប់មកផ្លាស់សម្លៀកបំពាក់ ហើយរៀបចំបម្រើអាហារដល់ខ្ញុំ។*

**រាកាង** *ន. ផ្គោង;* *ឧទា.* **ឆិះតើមឆីមាជានរាកាង ។** *យកឈើមកធ្វើផ្គោង។* *ព.ដ.៖* ងកាង ។

**រាកាំង** *ន. ទទឹង;* *ព.ផ្ទ.៖* ញជ្រិក។

**រាកាយ** *ន. អង្គុញ់;* *ព.ដ.៖* ក្លាច់។

**រាកាល់** *គុ. ល្អក់។*

**រាកុម** *ន. ចង្កោម, ធ្លាយ, ស្នែង។*

**ទូរាកុម** *មួយចង្កោម។*

**រាកើល** *កិ. កល់។*

**រាកេង** *កិ. ផ្អៀង។*

**រាកែ** *ន. ជ្រូកព្រៃ។*

**រាកែក** *កិ.វិ. អាការៈកត់ចំណាំអ្វីដែលគេនិយាយ ឬ ត្រងត្រាប់;*

*មើល៖* អា្យាត់។

**រាកែស**₁ *ន. រំកាច់;* *ឧទា.* **រាកែសឆី ។** *រំកាច់ឈើ។*

*មើល៖* នហេក។

**រាកែស**₂ *កិ. លួស;* *ឧទា.* **រាកែសងគីងឆី ។** *លួសមែកឈើ។*

**រាកែស**₃ *កិ. រករឿង។*

**រាកៃ** *ន. ដង្កៃ។*

**រាក្លាក់** *កិ.វិ. ស្ងាត់ស្ងៀម;*

*មើល៖* គុ។

**រាក្លាយ្យ** (*ព.ក្ង.៖* រាក្លាយ) *កិ.* ១) *រំដោះ,* ២) *ស្រាយ, ដោះ។*

**រាក្លាះ** *កិ. កែច្នៃ។*

**រាក្លុត** *ន. អង្កត់;* *ឧទា.* **រាក្លុតឆី ។** *អង្កត់ឈើ។*

**រាក្លើង** *កិ. គង;* *ឧទា.* **ឆិក់តីរាក្លើងនទ្រាងក្លែង ។** *យកដៃគងថ្ងាស។*

**រាក្លើយ** *កិ. ចោល;* *ព.ដ.៖* ងក្លើយ។

**រាក្លេ** (*ព.ក្ង.៖* រាក្លែ) *គុ. ស្អុះ;*

*ឧទា.* **ព្លៃរាក្លេ ។** *ផ្លែស្អុះ។*

**រាក្លេត** *កិ.វិ. ល្ងម;* *មើល៖* ហើម។

**រាក្លែស** *ន. ត្រសេះ។*

**ឆ្យុមរាក្លែស** *សត្វត្រសេះ។*

**រាខាត** *កិ.* *កកិត, ត្រដុស។*

**រាខាល់** *គុ.* *ល្អក់;* *ព.ផ្ទ.៖* រាឆាង។

**រាខុក** *កិ.* *គ្រលុក;* ***ឧទា.*** **រាខុកផ្លែក្រែងលាប់ជាសមិស ។** *គ្រលុកផ្លែព្រីងឱ្យចូលជាមួយអំបិល។*

**រាខូល** *កិ.* *ប្រំដែល;*
***ឧទា.*** **ង៉ើយរាខូល ។** *និយាយប្រំដែល។*

**រាខេល** *កិ.* *ព័ទ្ធស្ទាក់។*

**រាខែក** *ន.* *សត្វស្វាបមួយប្រភេទតូចជាងសត្វកេងកង។*

**រាខ្វាក** *កិ.* *រំខាន, ពពាំង។*

**រាគាក់** *ន.* *មាន់ទោរព្រៃ។*

**រាគាញ់** *គុ.* *ហត់, អស់កម្លាំង។*
**រាគាញ់រាគោញ** *ហត់នឿយ។*

**រាគាន់** *កិ.* *ឆ្ងង, ឆ្ងងកាត់;*
*មើល៖* ច្វាស, ក្លាត់។

**រាគាន់ក្រែក** *គុ.* *ត្រឹម;* ***ឧទា.*** **ទែសរាគាន់ក្រែកទុតនតុកនថិយ ។** *បាក់ត្រឹមកន្ទែងត។*

**រាគាល់** *កិ.* *កាប់ជាកង់។*

**រាគឹល** *កិ.* *ដូរ, 'ត្អូរ';*
*ព.ជ.គ្រ.៖* រាគិល់ 'ព្យ៉ាត់'។

**រាគឹប** *កិ.វិ.* *ប្រង៉ោ;* *មើល៖* គុ។

**រាគុក** *កិ.វិ.* *ព្រូ;* *មើល៖* លោស។

**រាគូ**₁ *កិ.វិ.* *ផ្អឹង;* *មើល៖* គុ។

**រាគូ**₂ *កិ.* *អង្រួន;*
*មើល៖* រាយុល, ញចាស។

**រាគូម** *កិ.* *ប្រមូល។*
**រាគូមរឹងមាល់** *ប្រមូលឱ្យជុំគ្នា។*
**រាគូមមាល់** *ប្រកបគ្នា។*

**រាគើប** (*ព.ក្ង.៖* រាគឹប) ***កិ.វិ.*** *អណ្ដែតអណ្ដូង;* *មើល៖* គុ។

**រាគេន** *ន.* *ចិញ្ចៀន។*

**រាគែល** *គុ.* *រួយ;* ***ឧទា.*** **រាគែលតី ។** *រួយដៃ។*

**រាគែ** *គុ.* *ស្គម។*
**រាគែរាអ្យារ** *ស្គមស្គាំង។*

**រាគិល់** *កិ.* *ផ្លាស់ប្ដូរ, 'ព្យ៉ាត់';*
*ព.ជ.គ្រ.៖* រាគឹល 'ត្អូរ'។

**រាគិះ**₁ (*ព.ក្ង.៖* រិះ) ***ធ.*** *តាម;*
***ឧទា.*** **រាគិះត្រិង ។** *តាមផ្លូវ។*

**រាគិះ**₂ *កិ.* *ទៅតាមមកវិញ។*

**រាគ្លិស** *កិ.* *រង្គើ។*

**រាង** *កិ.* *វែង;* ***ឧទា.*** **មេះរាងផៃ ។** *ម៉ែវែងអង្ករ។*

**រាង់** *ន.* *ពាំង។*
**តើមរាង់** *ដើមផ្ទឹកពាំង។*

**រាងគុស** *ន. រនូត។*

**ងគិល់** (*ព.កូ.៖* រាងគិល់) **ន.** *នង្គ័ល។*

**រាងា** *ន. លូ។*

**រាងាច់** *កិ.វិ.អស់ហើយ, រួចរាល់ហើយ;*
*មើល៖* លោច។

**រាងាត់₁** *កិ.វិ. ឈឹង, 'ព្នុរ';*
*ព.ជ.គ្រ.៖* រាងិត់ *'ព្យ៉ាត់';*
*មើល៖* រិស។

**រាងាត់₂** *កិ.វិ. រលីង; ឧទា.* **លែះ រាងាត់ ។** *អស់រលីង។*

**រាងាយ្យ** *ន. ពិធីជប់លៀងសងគុណ។*

**រាងាល់** *ន. ស្របក់; ឧទា.* **មិចទូ រាងាល់ ។** *ដេកមួយស្របក់។*

**រាងីរ** *កិ.វិ. ក្រឡោត; ឧទា.* **មាត់ រាងីរ ។** *ភ្នែកក្រឡោត។*

**រាងឹ** *គុ. រពឹសដៃ; ឧទា.* **កិនឆៃរាងឹ ។** *ក្មេងរពឹសដៃ។*

**រាងើត** *កិ. រលត់។*

**រាងេល** *គុ. ស្ពឹក។*

**រាងែង** *ន. ល្បៀង។*

**រាងែស** *កិ. កំដរ។*

**រាងោច** *កិ.វិ. រលីង;*
*មើល៖* លែៈរាងោច។

**រាងោញ** *កិ. កម្រើក, 'ព្រៃស';*
*ព.ជ.គ្រ.៖* ងគោញ *'ព្នុរ'។*

**រាងិក** *ន. ខួរ។*

**រាងិត** *កិ. កើតទុក្ខ។*

**រាងិត់** *កិ.វិ. ឈឹង, 'ព្យ៉ាត់';*
*ព.ជ.គ្រ.៖* រាងាត់ *'ព្នុរ'។*

**រាងិន់** (*ព.កូ.៖*រាងឹន) *កិ. ស្ងប់ (គ្មានរលក); ឧទា.* **មៃអិន់ទាកអ្យារាងិន់ ។** *សូមឱ្យទឹកនេះស្ងប់ទៅ។*

**រាងិល** *ន. ភូមិចាស់ ឬ ទីកន្លែងចាស់ដែលគេបោះបង់ចោល។*

**រាងិះ** *កិ.វិ. ស្ងាត់ស្ងៀម;*
*មើល៖* គុ។

**រាង្លាច់₁** *កិ. ដោះស្រាយ, សម្របសម្រួល; ឧទា.* **ម្វារាញរាង្លាច់នាវតឹមលិក់ ។** *ចាស់ទុំដោះស្រាយជម្លោះ។*

**រាង្លាច់₂** *កិ. ចៀរ; ឧទា.* **រាង្លាច់រាពាក់ជិង់នទ្រោក ។** *ចៀរគន្ធាក់ជើងគោ។*

**រាង្លាប់** *កិ. រួបរួមគ្នា។*

**រាង្លាស** *កិ. បំបែក។*

**រាង្លៃ** *ន.* ១) *គ្រាប់,* ២) *រាយ។*
**ផៃរាង្លៃ** *គ្រាប់អង្ករ។*

**រាង្វែមិស** ពាក្យ។

**រាង្វែរាង្វាប់** ស្រះ។

**រាង្វាន់** កិ. លេប; ព.ដ.៖ រាវាន់។

**រាច់១** កិ. ឧទ្ទិស, ឧបកិច្ច។

**រាច់ព្រាស** សែនព្រេនបែបព្រហ្មញ្ញសាសនា; មើល៖ អោបព្រាស។

**រាច់២** ន. ចាប។

**រាចា** កិ. លាងជម្រះ។

**រាចូល** កិ. រា; ឧទា. **លើយឆិះជិង់ រាចូលទាក ។** កុំយកជើងរាទឹក។

**រាចោន** កិ.វិ. ក្រវៀន, ខ្វៀន; មើល៖ ខឹត។

**រាចិក់** ន. ១) កែវ, ២) កញ្ចក់។

**រាច្វាល់** ន. ដុំ; ឧទា. **រាច្វាល់នែស ។** ដុំដី។

**រាឆាង១** គុ. ថ្លា។

**រាឆាង២** ន. ទឹកថ្លា។

**រាឆាច១** គុ. ស្ទាត់ជំនាញ (ខាងភាសា); ឧទា. **ពាង់ម្ហាវងើយមូនិង រាឆាច ។** គាត់ចេះនិយាយភាសាពួងស្ទាត់ជំនាញ។

**រាឆាច២** កិ. បាចសាច។

**រាឆាប** ន. ស្រកា។

**រាឆិ** ន. ឪឡឹក, ល្ពៅ; ព.ដ.គ្រ.៖ តាងអាយ ប៉ាអូង។

**រាឆឹក១** គុ. ជូង់។

**រាឆឹក២** កិ.វិ. ពពុះ; មើល៖ មពុញ។

**រាឆឹយ** ន. ឆ្ងក។

**រាឆុង** កិ. ខ្ពុរ, ក្រឡុក។

**រាឆុងមមូង** ខ្ពុរមាត់។

**រាឆូត** កិ. លាប។

**រាឆែ** ន. ខ្សែ។

**រាឆែងគិន់** ខ្សែរយាង (ព័ទ្ធជុំវិញពោះដំរី); ព.ដ.៖ រាឆែនទុល។

**រាឆែច្បាង់** ខ្សែរយាង (ព័ទ្ធជុំវិញកន្ទុយដំរី)។

**រាឆែឆ្វាន** សរសៃពួរ។

**រាឆែនទ្រីង** ខ្សែសម្បកឈើ (ដើមសំពោង)។

**រាឆែរាវាក់** (ព.ក្ង.៖ ឆែរាវាក់) ខ្សែប្រវាក់។

**រាឆែមោះ** ខ្សែចងក្បាល។

**រាឆែម្រាត់** ខ្សែព្រ័ត្រ; មើល៖ ម្រាត់។

**រាឆែន** គុ. សែន។

**ទូរាឆែន** មួយសែន (១០០ ០០០)។

**រាឆោប** ន. សំណាកស្បែក។

**រាឆៅ** ន. *រោម។*

**រាឆៅរាឆ្រុល** *រោមស្រមូម។*

**រាឆិ** ន. *អក្សរ។*

**រាឆិក** ន. *សុក។*

**រាឆិង** កិ. *ធ្វើដំណើរទៅមកៗ។*

**រាឆិង់** ន. *កាំប្រមា, ព្រួញប្រមា។*

**រាឆិង់មាត់** ន. *រោមភ្នែក។*

**រាឆិន់** ន. *សម្បុក។*

**រាឆិប់** ន. *ឫស្សីមួយប្រភេទ។*

**រាឆិម់** ន. *ក្រសាំងទំហំ, ដីរមួយ ប្រភេទ។*

**រាឆិស** កិ. *ស្ដោះ។*

**រាឆ្រុល** គុ. *ស្រមូម;* មើលៈ រាឆៅ។

**រាឆ្វាន់** ន. *សម្បុក (សត្វស្វាប)។*

**រាជាង់** កិ. *បោះ។*

**រាជាប់** គុ. ១) *ហ្មត់ចង់;* ២) *ចំណាប់។*

**រាជាយ** កិ. *សំយុងអន្ទាយ។*

**រាជឹង** ន. *រពាក់។*

**តើមរាជឹង** *ដើមរពាក់។*

**រាជោន** កិ.វិ. *អៀនប្រៀន។*

**រាញ** គុ. *ចាស់។*

**រាញ់** គុ. *ស្លួត។*

**រាញា** ន. *ឈ្មោះ។*

**រាញាក់** កិ.វិ. *រវើក។*

**រាញាល់**, គុ. *ពិបាក;* ព.ដ.ៈ រេសនី។

